ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ២ លេខ ៣

ខែវិច្ឆិកា ព.ស. ២៤៩៣

ឆ្នាំសិក្សា ១៩៥០-១៩៥១

UE
E
GE
2
71

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ

ឧត្តមដ្ឋាន ភាសា .................... ៣

មធ្យមដ្ឋានទី ១ ភាសា ................ ៧

អាទិកដ្ឋាន ភាសា .................... ១១

កុមារដ្ឋាន ភាសា .................... ១៩

បរិវុច្ឆណាដ្ឋាន ភាសា .................. ២២

មធ្យមដ្ឋាន - ឧត្តមដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ .... ៣០

អាទិកដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ ........... ៤៥

មធ្យមដ្ឋានទី ១ នព្វន្ត-រង្វាស់រង្វាល់ -ធរណីមាណសាស្ត្រ ៥៥

បរិវុច្ឆណាដ្ឋាន-នព្វន្ត -រង្វាស់រង្វាល់ .......... ៦៤

កុមារដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ ........... ៦៩

មធ្យមដ្ឋាន - ឧត្តមដ្ឋាន វិទ្យាសាស្ត្រ ......... ៧៥

មធ្យមដ្ឋាន - អាទិកដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ៨៣

បរិវុច្ឆណាដ្ឋាន-កុមារដ្ឋាន-វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ៩០

លោកនីតិ (គ្រូបង្ហាក់) ................ ៩៧

មេសូត្រតែមាត់ ......................១០០

# ឧត្តមដ្ឋាន

## លោកតាទុំ

នៅក្នុងអតីតកាលដ៏ជ្រៅរាប់មិនបានដែលលោកតាសំពកដោយមនោរម្យ សូមលោកតាទទួលយកនូវអភិវាទយ៉ាងស្មោះសរនៃសេចក្ដីគោរពនិងសេចក្ដីកតញ្ញូរបស់ចៅ ពីព្រោះចៅបានដឹងជាក់ច្បាស់ថា លោកតាបានធ្វើប្រយោជន៍ឲ្យចៅច្រើនពន់ប្រមាណ ។ ចៅបានដឹងថា សេចក្ដីប្រឹងប្រែងឥតឈប់ឈររបស់លោកតា បានបន្ធូរសេចក្ដីទុក្ខលំបាករបស់ចៅ ។ លោកតាពុំបាននឹកក្នកដល់អនាគតកាលក៏មែនពិត ដោយបញ្ញាលោកតាមានពន្លឺខ្សត់ខ្សោយនៅឡើយ ម្យ៉ាងទៀតដោយលោកតាគ្មានឱកាសនឹងគិតដល់ការអ្វីក្រៅអំពីការចិញ្ចឹមជីវិតអាត្មាប៉ុណ្ណោះ តែលោកតាជាបុរស១មានសភាពជាអ្នកអង់អាច មានឧត្ដមគតិយ៉ាងវិសេស បានប្រានលោកតាទៅរកការអ្វីទាំងឡាយដែលជាការគាប់ប្រសើរ នឹងមានផលប្រយោជន៍ដល់មនុស្សលោក ។ លោកតាបានរស់នៅក្នុងសេចក្ដីក្រខ្សត់ក៏ពិតមែន តែលោកតាមិនបានរស់នៅឥតប្រយោជន៍ចំពោះ

សង្គមឡើយ ហើយវប្បវត្តិដែលលោកតាបានទទួលយ៉ាងអន់ថយពីនាយមក លោកតាបានបញ្ជូនមកកូនចៅក្រោយ ៗ យ៉ាងធូរទូលាយ ។ លុះដល់វេនខ្លួនវិញ កូនចៅទាំងនោះក៏បានខំប្រព្រឹត្តធ្វើឲ្យរបៀបចិញ្ចឹមជីវិតនោះកាន់តែវិសេសឡើង ៗ ។ អ្នកទាំងអស់ក៏បានបង់ដៃទៅលើវេទនាផ្សេង ៗ មានគ្រឿងចក្រជាដើម គឺដោយសារសេចក្តីត្រិះរិះគ្មានឈប់ឈរនឹង គ្មានរួញរាពុះពារឧបសគ្គគ្រប់ប្រការនៃមនុស្សលោកគ្រប់ជាន់នឹងគ្រប់សតវត្សរ៍ នេះហើយដែលជាបុព្វហេតុបង្កើតបានជារបស់វិសេសគ្រប់យ៉ាងដែលជាឧបករណ៍ធ្វើឲ្យមនុស្សលោកទៅកាន់អារ្យធម៌នឹងសេចក្តីសន្តិសុខបានដោយរួសរាន់ទាន់សម័យ ។

## ពាក្យពន្យល់

អតីតកាល=កាលដែលបានកន្លងផុតទៅហើយ ។

មនោរម្យ (មនោ = ចិត្ត) = ដែលជាទីរីករាយចិត្ត, ដែលគួរឲ្យសប្បាយក្នុងចិត្ត ។

អភិវាទ = សំពះ ។ ឧត្តមគតិ=បំណងធំបំផុតរបស់មនុស្សលោក(idéal) ។

សង្គម=ចំណោមមនុស្សទាំងឡាយ ។ វប្បវត្តិ=របៀបរកចិញ្ចឹមជីវិត ។

ឧបសគ្គ = សេចក្ដីលំបាកផ្សេងៗ ,សេចក្ដីជំទាស់ ។

សតវត្សរ៍ = កំឡុង ១០០ឆ្នាំ (Siècle) ។

ឧបករណ៍ = គ្រឿងតាំងឡាយដែលសម្រាប់យើងប្រើប្រាស់(instrument)

អារ្យធម៌ = សេចក្ដីចំរើន (progrès)

## ពាក្យចោទសួរ

ហេតុអ្វីបានជាចៅត្រូវធ្វើអកតិវេទចំពោះជីតា ?

លោកតាបានធ្វើអ្វីខ្លះចំពោះចៅ ?

លុះដល់វេនខ្លួនវិញ តើចៅត្រូវប្រព្រឹត្តដូចម្ដេចខ្លះ ?

## រឿងក្ងាននឹងអណ្ដើក

មានកាលមួយនោះ ក្ងានពីរនឹងអណ្ដើកមួយបានយកគ្នាជាមិត្ត ថ្ងៃមួយនៅគិម្ហន្តរដូវ ស្រាប់តែត្រពាំងដែលសត្វទាំងនោះពឹងពាក់អាស្រ័យរីងហួតស្ងួតអស់ទៅ ។

ក្ងានទាំងពីរក៏ពិភាក្សាគ្នាថា: "ឥឡូវនេះទឹកបឹងរីងហួតអស់ហើយ, បងអណ្ដើកពុំអាចនឹងស្ថិតនៅទីនេះបានទៀតឡើយ ហើយមុខជាផ្លាក់ខ្លួន

ទៅក្នុងសេចក្ដីលំបាកជាពុំខាន" ។ និយាយគ្នាដូច្នោះហើយក្ងានទាំងពីរក៏នាំគ្នាទៅជួបនឹងអណ្ដើក ហើយមានវាចាទៅកាន់អណ្ដើកថា៖ <<ស្រះនេះទឹកគ្រាំងរីងហួតស្ងួតអស់ហើយ អ្នកពុំអាចនឹងរកអាហារនៅទីនេះបានទៀតឡើយ ហេតុដូច្នេះ ចូរសំឡាញ់ខាំដំបងនឹងមាត់ឲ្យខ្ជាប់ យើងទាំងពីរនឹងពាំចុងដំបងទាំងសងខាង ហើយយើងនឹងនាំអ្នកទៅរកកន្លែងណាដែលមានទឹកច្រើន ។ នៅវេលាដែលអ្នកខាំដំបង, ចូរអ្នកប្រយ័ត្នកុំនិយាយថាអ្វីឲ្យសោះ >>

ថាដូច្នេះហើយក្ងានក៏ពាំដំបងនឹងចំពុះហើយហើរកាត់ស្រុកនានា ។ មានកុមារជាច្រើនឃើញអណ្ដើកនៅលើអាកាសវេហាស៍នាំគ្នាស្រែកថា៖ លោកអើយមើលនុ៎ះន៏! ក្ងានពីរហោះពាំអណ្ដើកមួយនៅចំពុះ "

ដោយក្មេងទាំងនោះស្រែកពោលដូច្នេះជាច្រើនដង អណ្ដើកទឹកខឹងហើយនិយាយទៅកាន់ក្មេងថា៖ <<អ្នកឯងសុទ្ធតែជាសត្វលា ចូរនៅឲ្យស្ងៀម>> ដូច្នេះអណ្ដើកក៏លែងដំបងធ្លាក់ចាកចុះមកដីបានដល់នូវមរណកាលទៅហោង ។

## ពន្យល់ពាក្យ

គិម្ហន្តរដូវ = គឺរដូវក្ដៅ – រដូវរងាហៅហេមន្តរដូវ – រដូវភ្លៀងហៅវស្សន្តរដូវ ។

អ្នកសុទ្ធតែជាសត្វលា = (សត្វលាគេទុកជាសត្វដែលល្ងង់ទៀត) អ្នកសុទ្ធតែមនុស្សល្ងង់ខ្លៅមិនដឹងការអ្វី ៗ មរណកាល = សេចក្ដីស្លាប់ ៗ

## ពាក្យចោទសួរ

មុននឹងហោះហើរទៅលើអាកាសក្ងានបានផ្ដាំអណ្ដើកថាដូចម្ដេច ? តើអណ្ដើកបានធ្វើតាមពាក្យបណ្ដាំនេះទេ ? ហេតុអ្វីបានជាអណ្ដើកបានដល់នូវមរណកាល ? រឿងនេះបានជាគតិយ៉ាងដូចម្ដេច ?

# មជ្ឈិមដ្ឋានទី១

## រៀនមើល–ពាក្យភាសា

### រឿងសត្វកន្ធង់នឹងគីង្គក់

មានសត្វកន្ធង់មួយ ហើរក្រេបកេសរផ្កានាកណ្ដាលផ្លូវ បានយល់គីង្គក់មួយលោតទៅខាងគុម្ពផ្កា ទើបសួរថា បងគីង្គក់ទៅណា? គីង្គក់ជាសត្វអួតប្ញទ្ធិគិតថាអញនឹងប្រាប់គតិនេះឲ្យកន្ធង់គោរពខ្លាចអញ គិតហើយ

ទើបប្រាប់ថា យើងទៅកាន់មហាស្រះឯព្រៃហេមពាន្ត ដើម្បីនឹងបង់ស្រី

អើកន្ធង់ឯងកោតយើងនេះឬទេហ៎ះ? ។

ឯកន្ធង់តបថា បងឯងអាចទៅដល់ឬ?ព្រៃហេមពាន្តនៅឆ្ងាយម៉្លេះៗ ទុះយើងទៅវិលល្ងាចផង៍ណាកន្ធង់ ឯងសង្ស័យអ្វីឫទ្ធិយើងនេះ អើខ្លួននៅ ឯងតើធ្វើអ្វីនៅនេះ ឬសួរដឹងៗនោះ?

កន្ធង់បានទុកាសក៏តបថា យើងហើរប្រទក្សិណភ្នំព្រះសុមេរុ៍ ណាបងតីង្គក់ៗ ទុឯងហើរប្រទក្សិណភ្នំព្រះសុមេរុ៍នោះធំម៉្លេះបានឬ? អើ យើងហើរប្រទក្សិណភ្នំមួយថ្ងៃបាន៧ជុំផង ណាបងគីង្គក់ បងឯងខ្លាចឫទ្ធិយើងឬទេ?

ឯគីង្គក់នោះក៏តបកាត់ឡើងថា ខ្មោចអាឯងស្លាបមួយសុញទេទៅ អួតករថា ហើរប្រទក្សិណភ្នំព្រះសុមេរុ៍ មួយថ្ងៃ៧ជុំបាន អាណាទៅជឿឯងបាន ។

ឯកន្ធង់តបថា ខ្មោចអាឯងជើងខ្លីមួយសុញទេ ក៏អួតករថាឯងទៅដល់ព្រៃហេមពាន្ត វិលល្ងាចវិញបាន អាណាទៅជឿឯងបាន ។ គីង្គក់ក៏ទាល់ឈប់ស្ងៀមទៅ ។

ពន្យល់ពាក្យ.- ក្រេបកេសរ = ជញ្ជក់បឺតទឹកដមផ្កា ។ កន្ធង់ = កមរជាតិ គឺសត្វល្អិតពួកឃ្មុំ ។ ឫទ្ធិ = អានុភាព, អំណាច ។ គតិ = ដំណើរដើរ ។ មហាស្រះ = ស្រះធំ ។ ព្រៃហេមពាន្ត = ព្រៃមានទឹកកក, ទឹកសន្សើមជាប ។ សង្ស័យ = ឆ្ងល់, ជឿមិនស៊ប់ ។ ឱកាស = ចន្លោះពេល, ពេលទំនេរ ។ ប្រទក្សិណ = ហើរដ៏ទ្ឋជុំវិញវិលទៅស្តាំ ។ សុមេរុ - ស្តេចភ្នំកណ្តាលលោក ។ ១ សុញ - ១ ថ្នាំងម្រាមដៃ ។ ករ = និយាយពាក្យមិនពិត, ពាក្យកុហក ( អួតលេង ) ។

ពាក្យសួរ.- ក្នុងរឿងនេះគេនិយាយពីអ្វី?- កន្ធង់និងគីង្គក់ជួបគ្នានៅទីណា? - កន្ធង់និយាយទៅកាន់គីង្គក់ថាដូចម្តេច?- គីង្គក់គិតយ៉ាងដូចម្តេចមុននឹងឆ្លើយតបទៅកន្ធង់?- កន្ធង់ផ្ចាញ់ផ្ចាល់ទៅគីង្គក់វិញដោយវាចាថាដូចម្តេច?- អ្នកយល់ឃើញថាសេចក្តីអំនួតទៅជាដូចម្តេច? ។

## សរសេរតាមសូត្រ

### អំពីកាយដីហើយនិងជំរះស្មៅ

( កៀត្រសាស្ត្រទំព័រ ៤២ ) ពីដើមរហូតដល់ .. ហើយមានប្រយោជន៍ណាស់ ( សង្កាត់ទី ៣ ) ។

ពាក្យពិបាក — ជួរ - ក្ខួរ - សន្សើម - គារ - ផល - ធាតុ - យូរ - ប្រយោជន៍ - សោះទឹក ។

បទវេយ្យាករណ៍ ៖— ជ្រួយ = បំផុតដី កុំច្រឡំនឹងជ្រោយ = ប៉ែកដីលយទៅក្នុងសមុទ្រ ។ ក្ខួរ = អក្សរ ក; អក្សរ ខ ផ្ញើជើង ខ គ្មាន បញ្ញត្តិឲ្យប្រើឡើយ ។

សន្សើម = ព្យាង្គតម្រួត ។ ផល = ឥតសញ្ញាបន្តក់ ។

សោះទឹក = វិសជ៌នី ដូចពាក្យ ទោះ នោះ កោះ ។

(១) ទណ្ឌឃាត សំរាប់បដិសេធអក្សរលើសពីអានដូចពាក្យគោរព៌ ប្រយោជន៍ ការណ៍ ។ ទណ្ឌឃាតមិនបដិសេធជើងអក្សរឡើយ គេសរសេរ= អាទិត្យ-សិប្ប-វស្ស . . . វិសជ៌នី (ះ) ប្រើតែលើពាក្យកើតពីស្រៈ អ អុ អិ អេ អោ ដូចពាក្យ ជំរះ (អ) ដុះ (ុ) ដិះ (ិ) នេះ (េ) ក្រោះ (ោ) ។

ព្យាង្គតម្រួត = ព្យាង្គតម្រួតជាពាក្យមានព្យាង្គពីរបញ្ចូលគ្នា ។ ទឹងដឹង ព្យាង្គតម្រួត កាលណាព្យាង្គទាំងពីរដាក់ពយគ្នាទៅព្យាង្គមួយៗគ្មានសព្ទប្រែ ដូចពាក្យសន្សើមបើសរសេរសន់សើម សន់ប្រែមិនបានសើម ប្រែខុសសំដៅពីសន្សើមៗ ទឹងតម្រួតគ្នា កាលណាព្យាង្គដំបូងមានអក្សរ

ប្រកបហើយព្យាង្គបន្ទាប់កើតពីអក្សរនៅក្នុងវគ្គជាមួយគ្នា នឹងត្រូវប្រកបនៃព្យាង្គដំបូងនោះ ដូចពាក្យ សណ្តែក – ដ នឹង ណ វគ្គជាមួយគ្នា ។ ប៉ុន្តែ – ត នឹង ន វគ្គជាមួយគ្នា ។ តែបើព្យាង្គបន្ទាប់កើតពីអក្សរ អវគ្គ គឺ យ រ ល វ ស ហ ឡ នឹងត្រួតគ្នាបានដូចពាក្យ សន្សើម – ស ក្រោម ន ព្រោះពួកអវគ្គ ។ បើព្យាង្គដំបូងគ្មានអក្សរប្រកប ឬ ប្រកបនឹង ន ដូច្នេះ ពុំដែលត្រួតគ្នាឡើយ ។

# វាជិកដ្ឋាន

## បង្រៀនពាក្យ–ហាត់ភាសា

### អាទិត្យទី ១ – អំពីភូមិ

នាម.– ភូមិ, ឃុំ, ស្រុក, ខេត្ត, សាលាឃុំ, មេឃុំ, ផ្លូវ, ផ្លូវថ្នល់, ផ្លូវដើរ, របង, ទ្រុង, ក្រោលគោ, រដូវវស្សា, រដូវប្រាំង–រំហើយ ។

គុណនាម.– ទូលាយ, ចង្អៀត, ពិបាក, ងាយ, ស្រួល, ខ្ពស់, ទាប ។

កិរិយាសព្ទ.– កភូមិ, សង់ផ្ទះ, ដើរកាត់ភូមិ, ចុះពីផ្លូវធំ, ឡើងមកផ្លូវធំ, ធ្វើរបង ។

ហាត់និយាយ.— អ្នកនៅភូមិណា?— ភូមិនោះធំឬតូច?— មានផ្ទះប្រហែលប៉ុន្មាន?— អ្នកស្រឡាញ់ភូមិអ្នកឬទេ?— ពីព្រោះអ្វី?— សាលាឃុំនៅត្រង់ណា?— អ្នកដែលទៅសាលាឃុំឬទេ?— គេទៅសាលាឃុំដើម្បីអ្វី?— នៅភូមិអ្នកមានផ្លូវថ្នល់ឬទេ?— មានផ្លូវដើរប៉ុន្មាន? មកសាលារៀនអ្នកដើរតាមផ្លូវណា?— នៅជុំវិញភូមិអ្នកមានរបងឬទេ?— ព្រោះអ្វី?— ក្នុងរដូវវស្សាទឹកលិចភូមិអ្នកឬទេ?— ព្រោះអ្វីបានជាទឹកមិនលិច?— ហេតុអ្វីបានជាមានភូមិខ្លះទឹកលិច?— អ្នកស្រឡាញ់ភូមិអ្នកឬទេ? ព្រោះអ្វី?

## បង្រៀនមើល

### អំពីភូមិខ្ញុំ

សៀវភៅវិជ្ជាខេមរភាសាបរិច្ឆណ្ណឋានទំព័រ១២

កែតម្រូវ— កុំពង់ = កំពង់ ។ ថ្មរ = ថ្ម ។ ផុក = ភក់ ។

ពន្យល់ពាក្យ.— ភូមិ = ទីដែលមានប្រជុំផ្ទះលំនៅក្នុងតំបន់និមួយៗ ។

ក្រុង= កិ. គ្របដោយប្រដាប់មានអន្ទ្រុតជាដើម ហើយសង្កត់ទប់ទុក "ក្រុងមាន់ ឬ ក្រុងត្រី" ។

ក្រុង= (ច្រើនអានថាគ្រុង) ន. នគរ, រាជធានី, បុរី, "ក្រុងប៉ារីស, ក្រុងព្រៃនគរ, ក្រុងភ្នំពេញ" ។

ថ្លុក = ទីដីក្រហូងដែលដក់ទឹកភ្លៀងក្នុងរដូវវស្សា តែតូចជាត្រពាំង ។

ត្លុក = អ្នកក្រមាប់ អ្នកកំប្លែង ក្នុងល្បែងរបាំ ដើម្បីឲ្យគេសើច ។

## សរសេរតាមសូត្រ

អំពីភូមិខ្ញុំ (សៀវភៅដដែលទំព័រ ១២) តាំងពី ភូមិខ្ញុំនៅជិតក្រុង... រហូតដល់ ពិបាកដើរទៅភូមិឬឡើងមកផ្លូវធំ ។

សរសេរពាក្យពិបាក.– ផ្លូវកាត់ភូមិ, ក្រាលថ្ម, ដើរ, រដូវវស្សា, ដក់ទឹក, ភក់ ។

## តែងសេចក្តី

ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖

ភូមិខ្ញុំនៅជិត...... ដែលមកពីភ្នំពេញទៅឯ..........

..... ។ នៅក្នុង ....... មានផ្ទះ ... ផ្ទះទាំងនោះ ... ខ្ពស់ពីដី ហើយមាន ..... ព័ទ្ធជុំវិញ ។ កាលណាភ្លៀង ផ្លូវទាំងប៉ុន្មានក្នុងភូមិ ..... ដើរណាស់ព្រោះផ្លូវទាំងនោះមាន .... ច្រើន ។

### អក្សរផ្ចង់

ប ឞ ម ឃ ឋ

ប បា បី បូ បួ បើ បែ បៃ បោ បៅ

ភូមិពោមបៅ កុំបបេស បបើងបង់លាភ ។

### អានទី ២.— អំពីផ្សារ

នាម.— ផ្សារ, ផ្លូវរទេះឡាន, សសរ, ឥដ្ឋ, បាយអ, ដំបូល, ភ្លើង, ទំហំ, ជញ្ជាំង, ល្វែង, អ្នកលក់, អ្នកទិញ, ត្រី, សាច់, បន្លែ, ផ្លែឈើ, មាន់, ទា ។

គុណនាម.— ធំ, ទូលាយ, ចំហ, បិទជិត, ស្រស់, ក្រៀម, ឆាប់, រស់ ។

កិរិយាសព្ទ.— ទៅផ្សារ, មកពីផ្សារ, លក់ ទិញ, ជជែកគ្នា, តថ្លៃ, ឈ្លោះគ្នា, ជេរគ្នា ។

ពាក្យនិយាយ.— នៅជិតភូមិអ្នកមានផ្សារឬទេ? ឪពុកម្តាយអ្នកទៅទិញអីវ៉ាន់នៅទីណា?- ផ្សារនោះយ៉ាងដូចម្តេច?- ដំបូលប្រក់អ្វី?- មានជញ្ជាំងឬទេ? បណ្តោយនឹងទទឹងផ្សារប្រវែងប្រហែលប៉ុន្មានម៉ែត្រ?

នៅក្នុងផ្សារបែកជាប៉ុន្មានល្វែង ? នៅល្វែងទី១មានលក់អ្វីខ្លះ ? គេលក់ត្រីនៅកន្លែងណា ? ជនជាតិណាលក់សាច់ជ្រូក ? មានលក់អ្វីទៀត ? នៅក្នុងផ្សារឮសូរយ៉ាងដូចម្ដេច ? ផ្សារនោះធុំក្លិនយ៉ាងណា ? មានគេបោសលាងរាល់ថ្ងៃឬទេ ? អ្នកចូលចិត្តទៅផ្សារឬទេ ? ហេតុអ្វី ? ។

## បង្រៀនមើល

ផ្សារនៅភូមិខ្ញុំ (សៀវភៅវិជ្ជាខេមរភាសា កុមារដ្ឋាន ទំព័រ១០៩ មេរៀនទី ១០)

## សរសេរតាមសូត្រ

សូមយកសេចក្ដីដែលបានបង្រៀនមើលខាងលើនេះ មកឲ្យសិស្សសរសេរតាមសូត្រផង ។ (ធ្វើដូចរបៀបមុន) ។

## អក្សរផ្ចង់

ប ប ម ហ ឋ ឡ

បំប៉ុ បំប៉ា បំបាក់ បំបែក បំអិនបបរ

# បង្រៀនពាក្យ-ហាត់ភាសា

## អាទិត្យទី៣ ១- ភាពល្អនៃស្រុកកំណើតរបស់ខ្លួន

សៀវភៅរដ្ឋខេមរភាសាបរិច្ឆណដ្ឋាន ទំព័រ ៣៧

នាម.- ស្រុកកំណើត, ប្រទេស សត្តមបុស្សី, ជ្រុងសួន, ផ្លូវតូច ៗ

គុណនាម.- យូរអង្វែង, ដទៃ, ល្អប្លែក, ក្រៃពេកណាស់ ៗ

កិរិយាសព្ទ.- ចេញពីស្រុកកំណើត, ត្រឡប់មកស្រុកកំណើត, មកជុំ, សួរសុខទុក្ខ, ស្រណោះអាឡោះអាល័យ ៗ

ហាត់ភាសា.- ក្នុងរឿងនេះគេនិយាយពីអ្វី ? ហេតុអ្វីបានជាបុរសនោះដើរចេញពីស្រុកកំណើត ?- ដល់បុរសនោះមកវិញ ពួកមិត្តសំឡាញ់ធ្វើយ៉ាងដូចម្តេចខ្លះ ? - កាលដែលបុរសនោះដើរទេសបានឃើញអ្វីខ្លះ? បុរសនោះអាឡោះអាល័យប្រទេសដទៃដែលល្អប្លែក ៗ ឬទេ ?- ព្រោះអ្វីបានជាបុរសនោះត្រឡប់មកអាឡោះអាល័យផ្ទះឪពុកម្តាយវិញ ?- ផ្ទះនោះប្រកអ្វី ?- មានដាំដើមឈើអ្វីខ្លះព័ទ្ធជុំវិញ ?- ៗ

# កាំបិតឫហារនៅវត្តភូមិបាក់ខ្នារ

សៀវភៅវិជ្ជាខេមរភាសា អាទិកដ្ឋាន ទំព័រ ១២៥-១២៦ ។

នាម.— ខេត្តពោធិសាត់ ភេនជ្ន ភ្នំក្រវាញ ទូកឆ្លាក់ រូបទេព ប្រណម្យ ប្រផ្នូល ហេតុ ។

គុណនាម.— បុរាណ ទំនើប ស្អាត កខ្វក់ អត់ឃ្លាន សំបូរណ៍

កិរិយាសព្ទ.— ផ្លាស់ប្តូរ ហូតកាំបិតពីស្រោម ប្រជុំធ្វើបុណ្យ ផ្សង មើលប្រផ្នូល កែហេតុ ។

ហាត់ភាសា.— វត្តភូមិបាក់ខ្នារនៅខេត្តណា ?— នៅវត្តនោះមានរបស់អ្វីប្លែក ។ ភេនជ្ននោះយ៉ាងណា ?— នៅក្នុងភេនជ្ននោះមានអ្វី ? កាំបិតនោះរបស់អ្នកណា ? ទ្រង់ទ្រាយកាំបិតនោះយ៉ាងដូចម្តេចខ្លះ ?— បើគេផ្លាស់ប្តូរទីកន្លែងកាំបិតនោះ តើនឹងកើតហេតុអ្វី ? គេធ្វើបុណ្យផ្សងប្រផ្នូលកាំបិតនៅខែណា — ថ្ងៃណា ?— អ្នកណាដែលត្រូវហូតកាំបិតនោះចេញពីស្រោម ?— គេឃើញអ្វីនៅកាំបិតនោះ បានទំនាយថាល្អ ?— ទំនាយថាអាក្រក់ ? ។

## សរសេរតាមសូត្រ

សុំឲ្យជ្រើសរើសសេចក្តីខាងលើនេះមកដាក់ឲ្យសិស្សសរសេរតាម គ្រូថាផង ។

## អក្សរផ្ចង់

ប ប ម ឋ ឃ

មេមុំមួរបារី, មិងម៉ែនមេម៉ាយ កុំមើលងាយគេ ។

## តែងសេចក្ដី

### ១ – អំពីភូមិ

ឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

អ្នកនៅភូមិអ្វី ? ភូមិនោះធំឬតូច ? ទទឹងបណ្ដោយមានប្រវែងប្រហែលប៉ុន្មាន ? មានផ្ទះចំនួនប៉ុន្មាន ? នៅជុំវិញភូមិអ្នកមានរបងឬទេ ? នៅផ្លូវស្រុកភូមិអ្នកលិចទឹកឬទេ ? នៅភូមិនោះមានដាំដើមឈើស៊ីផ្លែឬទេ ? អ្នកស្រឡាញ់ភូមិនោះឬទេ ? ព្រោះអ្វី ? ។

### អំពីផ្សារនៅភូមិអ្នក

ថ្ងៃមួយអ្នកជូនម្ដាយអ្នកទៅផ្សារ ចូរអ្នកនិយាយពាប់រៀបអំពីដំណើរនេះតាមរបៀបខាងក្រោម ៖

១– សេចក្ដីផ្ដើម ។ ២– ពេលវេលាដែលចេញដំណើរទៅ ។ ៣– ទៅតាមផ្លូវ ។ ៤– ដល់ទៅទីផ្សារអ្នកឃើញអ្វីខ្លះ? ៥– ម្ដាយអ្នកទិញអ្វីខ្លះ? ៦– អ្នកសប្បាយចិត្តឬទេ? ហេតុអ្វី? ។

អាទិត្យទី ៤.– សុំឲ្យសួរសាបង្រៀនគ្រប់វិជ្ជាទាំងអស់ តាំងពី អាទិត្យទី ១ ឡើងវិញ ។

# កុមារដ្ឋាន

## រៀនពាក្យ–ហាត់ភាសា

### អាទិត្យទី ១.– ខ្លួនមនុស្ស

ពាក្យ.– ខ្លួន, ក្បាល, អវយវៈគឺដៃជើង, ក, មុខ, លលាដ៍ក្បាល, មាត់, ច្រមុះ, ភ្នែក, ថ្ងាស, ត្រចៀក, ថ្ពាល់, កំភ្លៀន, ចង្កា, រន្ធច្រមុះ, រន្ធត្រចៀក ថ្គាម ។ ស្មា, ដើមទ្រូង, ពោះ, ខ្នង, ចង្កេះ, ស្លាបប្រចៀវ, ក្លៀក ។

ភាសា.– ឲ្យយកក្មេងម្នាក់មកឈរពីមុខក្មេងទាំងឡាយក្នុងថ្នាក់ រួចគ្រូបង្អុលប្រាប់លើរូបក្មេងនោះ ពាក្យរបស់សរីរៈរាងកាយដែលត្រូវបង្រៀន ឯណាខ្លួនរបស់អ្នក ។ (នេះខ្លួនរបស់ខ្ញុំបាទ) ។ ខ្លួនរបស់អ្នកខាងលើហៅអ្វី ។ (ក្បាល) ។ ចុះក្រោមក្បាលហៅអ្វី ។ (ក) ។ ចុះក្រោម ក

មក ។ (ដងខ្លួន) ។ ចំណែកខ្លួនត្រង់ណាខ្លះ ដែលហៅអវយវៈ ។ (ដៃជើង) ។ (សុំឲ្យធ្វើពាក្យសួរតាមលំនាំដែលយើងឲ្យដូច្នេះតទៅ)

## អាទិត្យទី២- ខ្លួនមនុស្ស (ត)

ពាក្យ- ដៃ, ដើមដៃ, កំភួនដៃ, ដៃ, ខ្នងដៃ, បាតដៃ, ម្រាមដៃ, កែងដៃ, កដៃ, មេដៃ, ចង្អុលដៃ, ចង្អុលខ្មោចឬម្រាមកណ្ដាល, នាងដៃ, កូនដៃ ។ ជើង, ភ្លៅ, កំភួនជើង, ជើង, ។ ជង្គង់, គន្ទាក់អាចម៍, ស្មង, កជើង, បាតជើង ខ្នងជើង, ភ្នែកគោ, ម្រាមជើង, មេជើង, កូនជើង, ម្រាមកណ្ដាល ។ ត្រគាក, កណ្ដៀតក្អម, គូថ, (ទីខាងក្រោមខាងមូល) បាលីទ្វារលាមក ។ កញ្ចឹងក, សៀតផ្កា, សក់, រោមឬលោម, ចិញ្ចើម, រោមភ្នែក, ពុកចង្កា, ពុកមាត់, ត្របក ។

## អាទិត្យទី ៣- ខ្លួនមនុស្ស (ត)

ពាក្យ- សាច់, ស្បែក, ឆ្អឹង, សរសៃ, ឈាម, ទឹកមាត់, ទឹកភ្នែក, ខ្ទុះ ទឹកមូត្រ, ខ្យល់ដង្ហើម, ដីបបរ ។ ដើប, ងក់, កើត, ដេក, ដើរ, ឈរ, អង្គុយ, រត់, ស្ទាប, អង្អែល, ចាប់, ពាល់, កាន់, លើក, ដាក់, មើល,

សម្ងឹង, ស្ដាប់, ហិត, ស៊ី, ផឹក, ស្រូប, និយាយ, យំ, ស្រែក, ទំពា ជាន់, ដិះ, ប្អែក, ទ្រាល, លោត, ស្ទាប, ប្រត់ រួញ, ដោល ។

## អាទិត្យទី ៤ – ខ្លួនមនុស្ស(ត)

ពាក្យ.– សុំឲ្យរកគុណនាមមកបំពេញបទ នឹងនាមដែលរៀនរួចហើយពីអាទិត្យមុនៗ ។- ក្បាលមូល, ខ្លួនធំ, ដៃវែង, កខ្លី, ស្បែកស្ដើង, សាច់ទន់, សរសៃយឺត, ឈាមក្រហម, ទឹកមាត់រាវ . . .

ភាសា.– ក្បាលមនុស្សមានទ្រង់ទ្រាយដូចម្ដេច ។ ក្នុងខ្លួនយើងតាំងមូលអ្វីខ្លះដែលមានសណ្ឋានវែង, ទន់ៗ . . . .

## រៀនមើល – សរសេរ

### អាទិត្យទី ១ – មេរៀនទី ៦ (វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១២)

ក្នុងអាទិត្យទី ១ នេះត្រូវបង្រៀនឲ្យចេះអក្សរ ១ មួយថ្ងៃតាំងពីគំនូរអក្សរ តាំងអក្សរផ្សំស្រះ (បំបែក)- ឯអក្សរព្យញ្ជនៈដែលរៀនហើយក៏ត្រូវសរសេរទុកនៅក្ដារខៀនជាប ដើម្បីឲ្យក្មេងឃើញជានិច្ច ។- នឹងបង្រៀនអក្សរមួយៗត្រូវរកពាក្យបណ្ដុះស្មារតីផងដូចបង្រៀនអក្សរ ធ ឲ្យ

ថា ង ងស័ក ងោក ស្ងួន . . . . ។ កាលបើក្មេងចេះស្គាល់តាំងសរ
សេរតួអក្សរតាំងស័ព្ទអក្សរ តាំងបំបែក ទើបផ្គុំព្យញ្ជនៈបំបែកក្តី ព្យញ្ជ-
នៈតួទទេក្តីជាពាក្យពីរឬបីមាត់ឲ្យមើល ឲ្យសរសេរចុះក្នុងសៀវភៅ ។

អាទិត្យទី ២ – មេរៀនទី ៧ ( ខេមរភាសាទំព័រ ១៤ )

ការបំណាំ- សុំឲ្យបង្រៀនអក្សរឬ កន្ទុងដួ- អក្សរដួគឺជតម្រួតទីងដើងប

អាទិត្យទី៣ មេរៀនទី ៨ ( វិជ្ជាខេមរភាសាទំព័រ ១៦ )

អាទិត្យទី ៤ មេរៀនទី ៩ ( សៀវភៅជវផែលទំព័រ ១៩-២១)

## បរិច្ឆេទណាជ្ជ័ន

### រៀនពាក្យ-ហាត់ភាសា

អាទិត្យទី ១ សិលាជាតិ

ពាក្យ.- ឲ្យគ្រូបង្ហាញព្រមតាំងប្រាប់ឈ្មោះសិលាជាតិផ្សេងៗ ដែលបាន ប្រមូលមកទុក ។

នាម.— ថ្ម, ថ្មដា, ថ្មកំបោរ, ថ្មក្រាត, ថ្មបាយក្រៀម, ថ្មរ៉ាន់, ថ្មកែវ, ថ្មថ្មើមអណ្តើក, ថ្មដែកកើង, ថ្មកក់, ថ្មធ្យូង ថ្មដីស, ថ្មត្បូង, ថ្ម-ដៃរគៀម, ថ្មត្បូងពេជ្រ, ថ្មកណ្តៀង ថ្មត្បូងទទឹម ឬថ្មត្បូងក្រហម ។

គុណនាម.— ថ្មធ្ងន់, ថ្មស្រួយ, ផុយ, រឹង, ទន់, ភ្លឺ, ក្រហម, បៃតង, ក្ដ, ធ្លុះពេញម្ខាង, កណ្តៀង, ពពាល, ខ្មៅ, ព្រាត, ស្រួច, រលើប, រលង់, រលក, ធ្វត, ក្ដាំង, ជីត, ខ្ចី, ចាស់ ។

កិរិយា.— ជីកយក, គាស់, វាយបំបែក, ក្រាល, ឆ្នៃ, ដុស, សំលៀង កិន, បុក, សង្កត់, រៀបចំ, ដុត, រំលាយ, បំផុស, ក្រឡឹង, ឆ្លាក់, តើង, បាក់, ប្រេះ, រលំ, របេះ ។

ភាសា— (ពាក្យទាំងអស់នេះត្រូវប្រើការបង្រៀន ១ អាទិត្យ) អ្នកបានឃើញការអ្វីខ្លះដែលធ្វើដោយថ្ម ។ ថ្មអ្វីខ្លះដែលអ្នកស្គាល់ ។ ថ្មក្រាតសម្រាប់ប្រើធ្វើអ្វីខ្លះ ។ ថ្មបាយក្រៀម ។ ថ្មកែវ ។ ថ្មដា ។

## រៀនមើល

មេរៀនទី១· ក្រុមជាងសង់ផ្ទះ (វិជ្ជាខេមរភាសាទំព័រ ៣៤)

ពាក្យពន្យល់.— ក្រុមជាង គឺជាងច្រើននាក់ធ្វើការជាមួយគ្នា ។ គ្រឹះ=តួផ្ទះ

សិតផ្ទាន = ឈូសសំអាត ។

អានពាក្យ.— រៀប (កុំប្រឡំនឹងរាប) ។ លាប (កុំប្រឡំនឹងលៀប

ដើមឈើមួយយ៉ាង) ។

## មេរៀនទី២- សិលា (វត្ថុស្វាធ្យាយន៍ បរិច្ឆេទជ្ជានទំព័រ ៧៦)

ពាក្យពន្យល់.— សិលា = ថ្មទាំងឡាយ ។ វិញ្ញាណ = ការដឹង

ដោយប៉ះពាល់

អានពាក្យ · វិញ្ញាណ ថាវិញញាណ ។ រាវ (កុំប្រឡំនឹងរៀវ ។

## មេរៀនទី៣- ប្រយោជន៍នៃថ្ម (វត្ថុស្វាធ្យាយន៍ទំព័រ ៧៧)

ពាក្យពន្យល់· គួតត្រដុំសគ្នា ។ កំបិត (ឡែកជាកាំបិត) គ្រឿងប្រើ

កាប់ឬកាត់ ។ រហែងថ្ម = ទីមានថ្មច្រើន ។

## សរសេរតាមសូត្រ

១ – ក្រុមជាងសង់ផ្ទះ (វិជ្ជាខេមរភាសាទំព័រ ៣៤)

ពាក្យប្រើញឹកញយ.— ការ, អ្នក, គ្រឹះ, ផ្ទ, ក្តារ, បង្អួរ, ទ្វារ, ល្អ ។

បទគន្លងវេយ្យាករណ៍.– សង់ សង; ចាក់ ចាក; ផ្ទាក់ ទឹង, ទឹក, (!) បន្តក់- បន្តក់ដាក់លើពាក្យសព្ទខ្លះដែលកើតពីស្រៈ អ នឹងស្រៈ អា លើអក្សរ ង, ញ, ត, ន, ប, ល, ស ។

២– សិលា (វគ្គស្វាធ្យាយទំព័រ ៧៦- សង្កាត់ខាងដើម)

ពាក្យប្រើញឹកញយ៖– សិលា, ថ្ម, សត្វ, ប្ដូរ, អាហារ, ខុស ។

បទវេយ្យាករណ៍- សិលា, កំរើក ។

៣– សិលា (ត) ដល់ចប់

ពាក្យពន្យល់.– រស=ជាតិក្លិន ឬរស់ · មានជីវិត ។ ជួនឬជួន ។

## តែងសេចក្ដី ១

ចូរបំពេញត្រង់កន្លែងចន្លោះដោយពាក្យគួរប្រើ ។

ដើម្បីនឹងសង់ផ្ទះគេរក ....... ជាច្រើននាក់ ។ ជាងខ្លះដឹក ....... នឹងជាំសសរ ខ្លះ....... ឈើធ្វើគ្រឿងខាងលើគឺ ....... ខ្លះឈូស ....... ធ្វើជាកំពល ធ្វើជាជញ្ជាំង ធ្វើជាទ្វារនឹងបង្អួច ។ ផ្ទះសង់ស្រេចហើយជាងគំនូរ ....... ថ្នាំ ជាងដែកដាក់ .......។

## មេសូត្រ

ឱសត្វកំភេម ស្លាបខៀវស្រងាត់ ល្អប្លែកជាងសត្វ អម្បូរភមរា ។

ឱសត្វកំភេម លេចមកពីណា ខ្យល់ពីឧត្តរា កំភេមមកដល់ ។

ក្មេង ៗ ឃើញហើយ ដេញចាប់រវល់ ប្រឹងរត់ខ្វាយខ្វល់ តាមចិត្តប្រាថ្នា ។

ពាក្យពន្យល់ .– កំភេម - ភមរជាតិពណ៌ខៀវស្រស់ ឃើញមានមកតែ ១ ឆ្នាំម្តង ។ ភមរា - ពួកឃ្មុំ កន្លង់ ។ ឧត្តរា - ខ្យល់ពីជើង ។ ចិត្តប្រាថ្នា - ចង់បាន ។

អានពាក្យ: ភមរា - ភៈមៈរា- ឧត្តរា - អ៊ុត . ត័ . រ៉ា ។

## រៀនពាក្យ–ហាត់ភាសា

### អាទិត្យទី ២ - សិលា (ត)

នាម .– ថ្មដែក, ថ្មស្ពាន់, ថ្មសំណ, ថ្មស័ង្កសី, ថ្មមានសិហេ ថ្ម មនោសិលា, ដីឥដ្ឋ ថ្មឥដ្ឋ, ដីខ្សាច់, លោហជាតិ, ដែក, ស្ពាន់, សំណ, ទិកិល, ស័ង្កសី, មាស, ប្រាក់, ។ លាយជាតិ, ទង់ដែង លង្ហិន, សំរិទ្ធ, ទង់ហ៊ុំ ។

គុណនាម.— ស្អិត, ជាប់, ស្រួយ, ប្រផេះ, លឿង, ស្ងួត, ទន់, រឹង, រលោងរលើប, ផ្អូក, ស, ណែន, ជ្រាក, ផុយ ។

កិរិយា.— សិតផែក, រំលាយ, សប់, ចាក់ពុម្ព, បង្វិរ, បំផុស, ច្រោះ, ត្រង, ដំ, ផែ, ជ្រលក់, ស្រោប, បញ្ឆាន់, ក្រឡឹង, ខាត់, កោស, រូស, សំអាតបញ្ចុះជាតិ, ដេញ, លាយ ។

## រៀនមើល

១- ថ្មកំបោរ (វត្ថុស្វាធ្យាយន៍បរិ. ទំព័រ៧៩)

២- អំពីប្រដាប់ប្រើការធ្វើស្រែចំការ (វិជ្ជាខេមរ.បរិ.ទំព័រ២១)

៣- ធ្យូងថ្ម-ប្រេងកាត (វត្ថុស្វា.បរិ.ទំព័រ ៨០)

## សរសេរតាមសូត្រ

១-អំពីប្រដាប់ប្រើការធ្វើស្រែចំការ (រឿងមើល)

២-ប្រយោជន៍នៃថ្ម (វត្ថុស្វា.បរិ.ទំព័រ៧៧ (សង្កាត់ដើម)

៣-ប្រយោជន៍នៃថ្ម, គ) ដល់ចប់ ។

## តែងសេចក្តី

សូមឲ្យតែងសេចក្តីទុកបន្ទោះឲ្យបំពេញពីគ្រឿងប្រដាប់ធ្វើស្រែចំការ ។

## រៀនពាក្យ-ហាត់ភាសា

### អាទិត្យទី ៣ - ទី ៤ - សិលា (ត)

នាម.- របស់ធ្វើដោយថ្ម, លាន, សសរ, ប្រាសាទ, ផ្ទៃ, ស្តូប, ស្ពាន, ថ្មសំលៀង, បដិមាឬប្រតិមា, ជន្ទាប់, ត្បាល់កិន, ត្បាល់បុក, កំបោរ, ម្សៅ, គោល, ត្បូង, ពុម្ព, ជើង, រូបសត្វ ។

គុណនាម.- កំបោរឆៅ, ម្សៅសុទ្ធ, ត្បូងល្អ, គោលខ្ពស់, ត្បាល់កិនរេច, ថ្មសំលៀងផុយ, បដិមាសម, ស្តូបស្កុតស្តក, ជន្ទាប់មូល ។

កិរិយា.- សង់ប្រាសាទ, បោះគោល, ដាប់ថ្ម, គ្រឡឹងជន្ទាប់, លាយកំបោរ, ព្រោះម្សៅ, បុក, កិន, ដាំត្បូង, ឆ្លាក់រូប, ចាន់រូប, ផ្តិតពុម្ព, រៀបថ្ម ។

## រៀនមើល

១ -អំបិល (វិគ្គស្វា. បរិ. ទំព័រ ៨២)

២- វត្តនៅភូមិខ្ញុំ (វិជ្ជាខេមរ . បរិវ. ទំព័រ៦២, ដល់ប្រណាំងគ្នាលេង)

៣- វត្តនៅភូមិខ្ញុំ (ត) ដល់ចប់

## សរសេរតាមសូត្របញ្ជាក់

១- ថ្នាំកំបោរ (វត្តស្ទា. បរិវ. ទំព័រ ៧៩, ដល់ដុតកំបោរ)

២- ថ្នាំកំបោរ (ត) ដល់ចប់

កែពាក្យឲ្យត្រឹមត្រូវ.- ខុស់) ឲ្យសរសេរ (ខុស) ; អិដ ឲ្យសរសេរ ឥដ្ឋ

៣- វត្តនៅភូមិខ្ញុំ (រៀនមើល- តាំងពី នៅខាងត្បូងព្រះវិហារ........ ដល់គ្នាលេង)

កែដំរូវ.- ត្បូង (ថ្បូង) ; វិហារ (វិហ៊ារ); ទូកង (ទូកង៉រ) ; បុណ្យ (បុណ្យ៍)

## តែងសេចក្តី ១

សូមឲ្យតែងសេចក្តីទុកបន្ទោះនឹងឲ្យបំពេញអំពីផាងរៀបឥដ្ឋជញ្ជាំង ។

## មេសូត្រត្រូវចាំមាត់

បទសុរិយាល្ងាចថ្ងៃ

សុរិយាល្ងាចថ្ងៃ ទន្សោងគោព្រៃ រកស៊ីដើរក្នុំ ហ្វូងតូចដោយតូច ហ្វូង

ធំដោយធំ រកស៊ីក្បែរក្ដំ ស៊ីស្មៅល្បាស់ព្រៃ ។

**រៀនមើល**

១- ថ្មមានដម្លៃ (វត្ថុស្គា.បរិ. ទំព័រ ៨៤)

២- លោហធាតុ (ទំព័រ ៨៦)

៣- ដែក (ទំព័រ ៨៨)

# ឧត្តមដ្ឋាន និង មជ្ឈិមដ្ឋាន

**គណិត**

អាទិត្យទី១ .— អំពីចំនួនទសភាគ ។

យើងបានឃើញថាគេចែកម៉ែត្រជា ១០ភាគស្មើគ្នា មួយភាគៗហៅថា ១ ដេស៊ីម៉ែត្រ (ឯលីត្រក៏ចែកជា ១០ ភាគដូចគ្នាដែរ) ដូច្នេះមួយដេស៊ីម៉ែត្រគឺជាខ្នាត១ក្នុងភាគ១០ នៃម៉ែត្រ ដេស៊ីលីត្រគឺជារង្វាល់១ក្នុងភាគ ១០ នៃលីត្រ ។

បើយើងយកទំមួយមកចែកជា ១០ ចំណែក ចំណែកនិមួយៗហៅថា ១ ក្នុងភាគ ១០ នៃ ១ គត់ ។

១ គត់ = ១០ ទសភាគ

មួយដេស៊ីម៉ែត្រ ១ ដេស៊ីលីត្រ (០ល,១) គឺជាចំនួនទសភាគ ។

អំពីសរសេរចំនួនទសភាគ .— ចំនួនទសភាគត្រូវសរសេរនៅខាងស្តាំចំនួនគត់តែកុំភ្លេចដាក់កណ្ដកសញ្ញាខណ្ឌចំនួនទាំងពីរនេះ

ឧបមា ៧ គត់ ៥ ក្នុងភាគ ១០ នៃ ១ គត់ត្រូវសរសេរ ៧,៥ ។

សូន្យគត់ ៨ ក្នុងភាគ ១០ នៃ ១ គត់ត្រូវសរសេរ ០,៨ ។

មើលចំនួនទសភាគ .— ត្រូវមើលចំនួនគត់មុនរួចមើលចំនួនទសភាគទៀត ។ បើចំនួនទសភាគខាងលើនេះជាម៉ែត្រឬជាលីត្រឬជាក្រាមនោះត្រូវមើលថា ប្រាំពីរម៉ែត្រ ៥ ដេស៊ីម៉ែត្រ (៧ម,៥), ប្រាំពីរលីត្រប្រាំដេស៊ីលីត្រ (៧ល,៥), សូន្យក្រាម ៨ ដក្រ (០ក្រ,៨) ។

លេខបូកចំនួនទសភាគ .— បូកលេខទសភាគក៏ដូចជាបូកលេខចំនួនគត់ដែរ តែត្រូវប្រយ័ត្នសរសេរចំនួនគត់ក្រោមចំនួនគត់ ចំនួនទសភាគក្រោមចំនួនទសភាគ ហើយកុំភ្លេចដាក់កណ្ដកសញ្ញានៅក្រោមខ្ទង់កណ្ដកសញ្ញា ។ ឧបមាៈ ២៥$^{r}$,០៧ បូកនឹង៣រៀល ។

២៥$^{r}$,០៧ នោះសិស្សច្រើនសរសេរចំនួនខុស

ខុសខ្ទង់ + ៣$^{r}$ ខ្ទង់ដូចខាងលើនេះ ។ ឯការដែល

២៥$^{t}$,០៧ ត្រូវនោះគឺតាំងលេខឲ្យចំខ្ទង់ដូចគំរូ

ត្រូវខ្ទង់ + ៣$^{t}$,០០ ខាងឆ្វេងនេះវិញ ។

២៨$^{t}$,០៧

ការហាត់.- ចូរធ្វើលេខខាងក្រោមនេះ ៖

១៧$^{ម}$,០៣៦ + ៣$^{ម}$,៥ + ២៣៩$^{ម}$,០២៨ =

៣៥ល,៦០ + ១០៧ល, + ០ល,២៨០ =

។ល។

បំណោទ.- ធុងទទេមួយទម្ងន់ ២៧ គក្រ,៥០០ គេយកប្រេងទៅចាក់ដាក់ធុងនោះចំនួន ១២៦ គក្រ,៣៦ លើសពីទម្ងន់ធុងទទេ ។ តើធុងមានប្រេងពេញនេះទម្ងន់ប៉ុន្មាន ? ។

អាទិត្យទី២.- ។ លេខសងចំនួនជាទសភាគ ។

របៀបទី ១ .- សងចំនួនទសភាគនឹងចំនួនទសភាគ ។

ឧបមា: ៤, ៨៧៧ − ៣, ៧៥៦ =

៤, ៨៧៧ ខ្ញុំត្រូវសរសេរចំនួនធំលើចំនួនតូចក្រោមដូច្នេះ គឺចំនួន

៣, ៧៥៦ គត់ក្រោមចំនួនគត់ ចំនួនទសភាគក្រោមចំនួនទស-

១, ១២១ ភាគរួចធ្វើលេខហូតដូចជាចំនួនគត់ដែរ តែខ្ញុំត្រូវដាក់

កណ្ដក់សញ្ញានៅចំនួនដែលសល់ចំខ្ទង់កណ្ដក់សញ្ញា ។

របៀបទី២.— ។ ចំនួនធំជាចំនួនគត់ ចំនួនតូចជាលេខទសភាគ ។ ឧបមា៖

២៣២ – ៤៨,៧៥ =

២៣២ ២៣២ នេះត្រូវតាំងលេខដោយពុំបាច់រវល់

–៤៨ – ៤៨, ៧៥ នឹងចំនួនទសភាគរបស់មបុះចំនួន

ទសភាគទៅខាងស្ដាំ ចំនួនគត់ខណ្ឌ

២៣២, ០០ គ្មានឹងកណ្ដក់សញ្ញាមួយ ឯចំនួន

–៤៨, ៧៥ គត់ខាងលើត្រូវបំបែកទៅជាចំនួន

១៨៣, ២៥ ទសភាគដូចគ្នាដោយដាក់សូន្យ

ជំនួស ហើយធ្វើលេខដូចជាចំនួនគត់នឹងចំនួនគត់ តែត្រូវដាក់កណ្ដក់សញ្ញាក្រោមខ្ទង់កណ្ដក់សញ្ញាជានិច្ច ។

របៀបទី ៣.— ចំនួនធំជាចំនួនទសភាគ ចំនួនតូចជាចំនួនគត់ ។ ឧបមា៖

៣៤៨, ៧៥ ៣៤៨, ៧៥ – ១២៥=

– ១២៥ នេះត្រូវធ្វើដូចលេខចំនួនគត់

២២៣, ៧៥ ដែរ ឯចំនួនទសភាគដែល

មានក្នុងចំនួនធំត្រូវបញ្ចុះតែម្ដង ព្រោះគ្មានចំនួនអ្វីយកទៅហូត ។

**ការហាត់** .— ចូរធ្វើលេខខាងក្រោមនេះ ៖

១០០ម៉ឺ ២ – ៣៨ម៉ឺ ៧៤ =

៤៥០, – ១៤៨,២ =

៦០៥,២៥ – ៤៣២ = (ល)

<u>បំណោទ</u> .— មនុស្សម្នាក់ជំពាក់បំណុលគេ ៤៧៨រ, ៥០ បានយកប្រាក់ទៅសងៈគម្តង ១២៥រ,៥០ ម្តងទៀត ៧៨រ,២៥ ដល់ក្រោយមក ១៤២រ, ៤៥ ទៀត ។ តើបុរសនោះនៅជំពាក់គេប៉ុន្មានរៀលទៀត ? ។

**អាទិត្យទី ៣** .— លេខគុណចំនួនទសភាគ ។

<u>របៀបទី ១</u> — គុណចំនួនទសភាគ នឹងចំនួនគត់ ។ ឧបមា: ពោតមួយហិកតូលីត្រថ្លៃ ៣៦ រៀល ៥០ តើពោត ៣ ហ.ល. ថ្លៃប៉ុន្មានរៀល ?

| | |
|---|---|
| ៣៦, ៥០ | ត្រូវធ្វើដូច្នេះ ៣៦, ៥០ × ៣ = ១០៩រ, ៥០ |
| × ៣ | គេគុណចំនួនទសភាគជា ៣ ដងរួចគុណចំនួនគត់ |
| ១០៩, ៥០ | ជា ៣ ដងទៀត តែកុំភ្លេចលេខដែលត្រាទុក ។ |

ម្យ៉ាងទៀត គេធ្វើលេខមិនគិតចំនួនទសភាគក៏បានដែរ ព្រោះគេដឹងថា ៣៦រ, ៥០ = ៣៦៥០សេន ។

| | |
|---|---|
| ៣៦,៥០ | ៣៦៛,៥០ × ៣ = ឬ ៣៦៥០ សេន × ៣ = |
| × ៣ | ១០៩៥០ សេន ឬ ១០៩៛,៥០ ។ |
| ១០៩,៥០ | តែត្រូវដាក់កណ្ដក់សញ្ញាគិតពីខាងស្ដាំទៅឆ្វេងតាម |

ចំនួនទសភាគដែលមានក្នុងចំនួនតាំង ។

របៀបទី ២.— គុណលេខចំនួនទសភាគនឹងទសភាគ ។

ឧទាហរណ៍៖ ពោត ១ ហាល ថ្លៃ ៣៦៛,៥០ តើពោត ៣ ហាល, ២ ថ្លៃប៉ុន្មានរៀល ? ។

យើងដឹងថាពោត ១ លីត្រថ្លៃ ..... ០៛,៣៦៥ យើងដឹងទៀតថា ៣ ហាល, ២ មាន...៣២០ លីត្រ ដូច្នេះត្រូវយក ០៛,៣៦៥×៣២០= ១១៦៛,៨០ លេខនេះត្រឡប់ទៅជាចំនួនទសភាគគុណនឹងចំនួនគត់ដូចបានអធិប្បាយក្នុងរបៀបទី ១ ខាងលើហើយ ។

| | |
|---|---|
| ៣៦៥០ | បើធ្វើលេខដដែលនេះមិនបាច់រលំនឹងចំនួន |
| × ៣២០ | ទសភាគក៏ឃើញដូចគ្នាដែរ គឺ |
| ៧៣០០០ | ៣៦៥០×៣២០=១១៦៛,៨០ |
| ១០៩៥០ | ដោយកាត់ចំនួនទសភាគ ២ ខ្ទង់ពីកណ្ដក់- |
| ១១៦,៨០០០ | |

សញ្ញា ព្រោះគុណលេខតាំងមានចំនួនទសភាគ២ខ្ទង់ គុណចំនួនមេគុណ មានទសភាគ២ខ្ទង់ទៀតជា៤ខ្ទង់ ។

**ការហាត់**.– ចូរធ្វើលេខខាងក្រោមនេះ ៖

| | |
|---|---|
| ៨៥៤២×២៦,៣៥= | ៤៩០៦×៦០,៨៤= |
| ៤៨៤,៧×៩៨៦= | ៨៦៧,៤×៩,៨៥= |

**បំណោទ**.– ក្នុងរថយន្តមួយ មានអ្នកដំណើរ១២នាក់ ចេញថ្លៃឈ្នួល២៥,៦០ម្នាក់ ឯអ្នកដំណើរ ១៥នាក់ទៀតចេញថ្លៃតែ៩,៧៥ម្នាក់ៗ តើម្ចាស់រថយន្តបានប្រាក់ទាំងអស់ប៉ុន្មានរៀល ? ។

## អាទិត្យទី ៤.– លេខចែកជាចំនួនទសភាគ ។

### របៀបទី១.– ចំនួនតាំងជាទសភាគ ។

**ឧទាហរណ៍** ៖ គេចង់កាត់ខ្សែលួសមួយបណ្ដោយប្រវែង៧៣ម៉ែ១៤ជា២៣ កំណាត់ស្មើគ្នា តើខ្សែលួស១កំណាត់ៗប្រវែងប៉ុន្មានម៉ែត្រ ? ។

| | |
|---|---|
| ៧៣,១៤ | ២៣ |
| ០៤ ១ | ៣១៨ |
| ១ ៨៤ | |
| ០០ | |

យើងដឹងថា ៧៣ម៉ែ១៤ មាន ៧៣១៤ សង់ទីម៉ែត្រ ដូច្នេះត្រូវយក ៧៣១៤ សម ជាចំនួនគត់ទឹង ២៣ ដែលជាចំនួនគត់ដែរ ហើយដែលយើងបានរៀនពីខមុនស្រាប់ ។ គឺ ៖

៧៣១៤ : ២៣ = ៣១៨ សម, ឬ ៣ ម, ១៨ ។

របៀបទី២ .— ចំនួនតាំងនិងដើមហារជាទសភាគ ។

ឧទាហរណ៍ .— បើចែកចំនួន ៥៨,៦៧ នឹង ៣,៤ នេះត្រូវគិតថា ក្នុង ៥៨,៦៧ មាន ៣,៤ ប៉ុន្មានដង ឬ ក្នុង ៥៨៦,៧ មាន ៣៤ ប៉ុន្មានដង នោះត្រូវយក ៥៨៦,៧ : ៣៤ = ១៧,២ ត្រង់នេះឃើញថា

| | | |
|---|---|---|
| ៥៨៦,៧ | ៣៤ | ឃើញអនុដើមហារ ៣,៤ ឲ្យ |
| ២៤៦ | ១៧,២ | ទៅជា ៣៤ (ចំនួនគត់) វិញ |
| ០៨ ៧ | | ដូចក្នុងរបៀបទី ១ ខាងលើ |
| សល់ ១ ៩ | | នេះដែរ ។ |

ការហាត់ .— ចូរធ្វើលេខខាងក្រោមនេះ ៖

| | |
|---|---|
| ៦៤រ,៧៥ : ២១ = ... | ៥៤៨ ក្រ ៧០ : ២៣ = ... |
| ២៣៤ ល,៥០ : ១៧ = ... | ៩៤២ ក្រ ៤០ : ៧,៣ = ... |

បំណោទ .— ឈើគូស ២២៥ ប្រអប់ថ្លៃ ១៦៥ រៀល ឈ្នួលដឹកនាំអស់ ២រ,៥០ ទៀត ហើយថែមទាំងបង់ពន្ធអស់ ១១រ,៧៥ តើត្រូវលក់ឈើគូសទៅវិញ ១ ប្រអប់ថ្លៃប៉ុន្មានឲ្យបានចំណេញ ៥៧រ,៥០ ? ។

ការគិតលេខនឹងប្រាជ្ញា .— គុណលេខនឹង ១៩ - ២៩ - ៤៩ - ៩៩ (ល) ។

នឹងគុណចំនួនឯណាទីមួយនឹង ១៩ - ២៩ ..... ៩៩ (ល) គេត្រូវគុណចំនួននោះនឹង ២០, ៣០, . . . ១០០ បើឃើញប៉ុន្មានៗយកចំនួនតាំងទៅហូតវិញនឹងឃើញចំនួនដែលត្រូវរក ។

ឧបមា ៖ ១៣ × ១៩ =

ត្រូវយក ១៣ × ២០ = ២៦០

ត្រូវយក ១៣ ទៅកាត់ចេញ ២៦០ − ១៣ = ២៤៧

ការហាត់ ៖— ចូរគិតលេខខាងក្រោមនេះ ៖

| | | |
|---|---|---|
| ៣៤ × ១៩ | ១៣ × ៣៩ | ៤២ × ២៩ |
| ៤២ × ១៩ | ៦៦ × ២៩ | ៥៧ × ៣៩ |
| ៣២ × ៥៩ | ១,៦ × ៤៩ | ៩,២ × ៩៩ |

## វង្វាស់វង្វាល់

### អាទិត្យទី ១ ៖— អំពីក្រឡាផ្ទៃ ឬ ផ្ទៃ ។

យ៉ាងម្តេចហៅថាផ្ទៃ ?.— សូមលោកគ្រូចង្អុលផ្ទៃផ្សេងៗបង្ហាញសិស្ស ដូចផ្ទៃក្តារខៀន ផ្ទៃឥដ្ឋក្រាល ផ្ទៃជញ្ជាំង ទីធ្លាៗ ល ។

នឹងវាស់ផ្ទៃយ៉ាងដូចម្ដេច ?.— នឹងវាស់ផ្ទៃគេត្រូវវាស់ដូចជាវាស់ប្រវែងដែរ តែរង្វាស់នោះគិតជាម៉ែត្រក្រឡា (ម$^{២}$) គឺគេយកម៉ែត្រ, ដេស៊ីម៉ែត្រ, សង់ទីម៉ែត្រ, ។ល។ វាស់ ព្រោះរង្វាស់សម្រាប់វាស់ផ្ទៃគ្មានទេ ។ រង្វាស់សម្រាប់វាស់ផ្ទៃជារង្វាស់ឥតរូប ។ ១ ម៉ែត្រក្រឡា (១$^{ម២}$) គឺជាផ្ទៃ ៤ ជ្រុងមានប្រវែង ១ ម៉ែត្រមួយជ្រុង ។

**បំណោទ** ·— ដីភូមិ ១ មានរាង ៤ ជ្រុងស្មើ ប្រវែង៦៧$^{ម}$ មួយជ្រុង តើដីនោះធំថ្លៃប៉ុន្មាន បើដី ១$^{ម២}$ ថ្លៃ ២ រៀល ។

**អាទិត្យទី ២** ·— អំពីរង្វាស់ដែលធំជាងម៉ែត្រក្រឡា ។

រង្វាស់សម្រាប់វាស់ផ្ទៃ តូចឬធំជាងគ្នា ១០០ ៗដង ។

១ ដេកាម៉ែត្រក្រឡា គឺជាផ្ទៃ ៤ ជ្រុងប្រវែង ១$^{ដាម}$ មួយជ្រុង ធំជាងម៉ែត្រក្រឡា ១០០ ដង ។

១ហិកតូម៉ែត្រក្រឡា (១$^{ហម២}$) មាន ១០០$^{ដាម២}$ ឬ ១០,០០០$^{ម២}$

១គីឡូម៉ែត្រក្រឡា (១$^{គម}$) មាន ១០០$^{ហម២}$ ឬ ១០.០០០$^{ដាម២}$ ឬ ១.០០០.០០០$^{ម២}$ ។

ដូច្នេះនឹងសរសេរចំនួនជាផ្ទៃគេត្រូវបែងជាខ្ទង់មានលេខពីរ ៗ មួយ

| គម២ | ហម២ | ដាម២ | ម២ |
|---|---|---|---|
| ០ ០ | ០ ០ | ០ ០ | ០ ០ |
| ៣ | ០ ៧ | ១ ៥ | ០ ៤ |

ខ្ទង់ ខ្ទង់ណាដែលអត់លេខគេដាក់សូន្យជំនួស ។ ចំនួនខាងលើនេះត្រូវមើលថា ៣ គម២ ១៧ ហម២ ១៥ ដាម២ ៤ ម២ ។

– ការហាត់ .– ឲ្យផ្លាស់ន័យជាម៉ែត្រក្រឡា ហើយបូក ៖

៣៧ ហម២ ៥០ + ៩០៥ ម២ + ៧ គម២ ,០៩ =

ប្ដូរផ្លាស់ន័យជាហិកតូម៉ែត្រក្រឡា ៖

២៧៦០០ ដាម២ ; ៣៩០០០ ម២ ; ៧ គម២ ៥ ដាម២

## អាទិត្យទី ៣ .– រង្វាស់ផ្ទៃតូចជាងម៉ែត្រក្រឡា ។

ដើម្បីនឹងកត់នឹងវាស់ផ្ទៃដែលតូចជាងម៉ែត្រក្រឡា គេប្រើដេស៊ីម៉ែត្រក្រឡា (១ ដម២) នឹងសង់ទីម៉ែត្រក្រឡា (១ សម២) ។

១ ដេស៊ីម៉ែត្រក្រឡា គឺផ្ទៃ ១ មានជ្រុងនិមួយៗប្រវែង ១ ដេស៊ីម៉ែត្រ ។ ឲ្យសិស្សគូសផ្ទៃ ១ ដម២ នឹង ១ សម២ នៅលើក្ដារខៀនគ្រប់ៗគ្នា ។

រង្វាស់ផ្ទៃដែលតូចជាងម៉ែត្រក្រឡា គឺ ៖

| | | |
|---|---|---|
| ១ ដេស៊ីម៉ែត្រក្រឡា (១ ដម២) | តូចជាងម៉ែត្រក្រឡា | ១០០ ដង |
| ១ សម២ | តូចជាងម៉ែត្រក្រឡា | ១០.០០០ ដង |
| ១ មម២ | តូចជាងម៉ែត្រក្រឡា | ១.០០០.០០០ ដង |

ការហាត់.– ចូរផ្លាស់ន័យជាម៉ែត្រក្រឡា ហើយធ្វើលេខខាងក្រោមនេះ ៖

$៧^{\text{ដម២}}$ $៣៥^{\text{ម២}}$ $៦^{\text{សម២}}$ + $៩៤៧៨១^{\text{ដម២}}$ $៣៩^{\text{សម២}}$ =

$៨^{\text{ហម២}}$ $២៩៧^{\text{ដាម២}}$ + $២៨៧^{\text{ដាម២}}$ $៩៣^{\text{ដស២}}$ =

បំណោទ.– បន្ទប់ ១ ក្រាលឥដ្ឋស៊ីម៉ងត៍ ៣៥២ បន្ទះ ទំហំ $២០^{\text{សម}}$ មួយជ្រុង តើបន្ទប់នោះទំហំប៉ុន្មានម៉ែត្រក្រឡា ។

## អាទិត្យទី ៤.– រៀនសារឡើងវិញ ។

# ធរណីមាណសាស្ត្រ

## អាទិត្យទី ១.– អំពីផ្ទៃកាង ៤ ជ្រុងស្មើ ។

ផ្ទៃកាង ៤ ជ្រុងស្មើ គឺជាផ្ទៃមានជ្រុង ៤ ប្រវែងស្មើគ្នាទាំងអស់ មុមទាំង ៤ ក៏ទំហំប៉ុនគ្នា ហើយជាមុមកែងផង ។




កខឃគ ជាផ្ទៃកាង ៤ ជ្រុងស្មើ ព្រោះជ្រុង កខ ប្រវែងនឹងជ្រុង ខឃ នឹង គឃ ហើយនឹង គក ។

ឯរង្វាស់សម្រាប់ប្រើក្នុងការរកក្រឡាផ្ទៃផ្សេងៗ គេប្រើម៉ែត្រក្រឡា ($១^{\text{ម២}}$) មើលថា ១ ម៉ែត្រក្រឡា ។

<u>អំពីរកផ្ទៃ ៤ ជ្រុងស្មើ</u> .— ទឹងរកផ្ទៃ ៤ ជ្រុងស្មើត្រូវយកប្រវែងជ្រុង (ជ្រ) គុណនឹងជ្រុង ។

ម$^2$ = ជ្រ × ជ្រ

រកជុំវិញឬរកបរិវេណ ។ ទឹងរកពាក់កណ្ដាលបរិវេណ ត្រូវយកជ្រុងគុណនឹង ២

ពាក់កណ្ដាលបរិវេណ = ជ្រ × ២

ទឹងរកបរិវេណត្រូវយកជ្រុងគុណនឹង ៤

ប = ជ្រ × ៤

**ការហាត់** .. ឲ្យគូសផ្ទៃ ៤ ជ្រុងស្មើ ១ ប្រវែង ៦ សម មួយជ្រុង ។

**បំណោទ** .. ស្រែបីមានទំហំផ្ទៃរួមគ្នា ៩ ហម២ ស្រែទី ១ ធំលើសស្រែទី ២ ៤៨ ដាម២ ៧ម២ ហើយតូចជាងស្រែទី៣ ៤៨០៧ម២ តើស្រែនីមួយៗមានទំហំប៉ុន្មានម៉ែត្រក្រឡា? ។

**អាទិត្យទី ២** .— អំពីផ្ទៃបួនជ្រុងទ្រវែង ។

ឲ្យសិស្សសង្កេតមើលក្ដារខៀនបញ្ឈរហើយឲ្យប្រដូចជ្រុង ១ នឹងជ្រុង ១ មុមមួយនឹងមុម ១ ឃើញថា ជ្រុងស្របគ្នាពីរៗ? យកកែងវាស់

មុមឃើញថាជាមុមកែង ។ ដូច្នេះផ្ទៃ ៤ ជ្រុងទ្រវែងគឺជាផ្ទៃមានមុមកែង ៤ មានជ្រុងជាបន្ទាត់ស្របគ្នាពីរៗ ហើយប្រវែងគ្នាពីរៗ ; មានប្រវែងពីរ




យ៉ាងផ្សេងគ្នាគឺបណ្តោយ (ប) និងទទឹង(ទ) ; ជ្រុងដែលវែងហៅថាបណ្តោយ ជ្រុងខ្លីហៅថាទទឹង ។

ពាក់កណ្តាលបរិវេណ = ប + ទ

បរិវេណ = ប + ទ × ២

ម$^{2}$ = ប × ទ

បំណោទ.– ក្នុងគេហដ្ឋានមួយមានបង្អួច៨មានកញ្ចក់២០បន្ទះក្នុងបង្អួចមួយៗ ។ កញ្ចក់១ទំហំ១៤ ដ.ម ២ ឯកញ្ចក់ព្រមទាំងថ្លៃដាក់ស្របថ្លៃ ២៥ រៀលមួយម៉ែត្រក្រឡា ។ តើបង្អួចកញ្ចក់ផ្ទះនោះថ្លៃប៉ុន្មាន ? ។

អាទិត្យទី ៣.– អំពីផ្ទៃ៤ជ្រុងព្នាយស្រប ។

សូមគ្រូគូរផ្ទៃ៤ជ្រុងទ្រវែង១នៅក្តារខៀនបញ្ឈរ ក ខ គ ឃ



ហើយឲ្យសិស្សប្រដូចជ្រុង, ប្រដូចមុម, ដូចបានធ្វើកន្លងអា-ទិត្យទី២អំពីផ្ទៃ ៤-ជ្រុងទ្រវែងរួចហើយ ។

រួចសូមគ្រូគូសកាត់ជាផ្ទៃត្រីកោណស្វាបក្ដោង ក ប ឃ ពីខាងឆ្វេង យកទៅបន្ថែមខាងស្ដាំបានជាផ្ទៃ១ផ្សេងទៀត ហើយឲ្យសិស្សពិនិត្យមើលជ្រុងបណ្ដោយ ឃ គ ដែលយើងមិនបានប៉ះពាល់ទេនៅដដែល ឯបណ្ដោយ ក ១ យើងកាត់ពីខាងឆ្វេងយកទៅបំពេញខាងស្ដាំ ដូច្នេះបណ្ដោយថ្មីនេះប្រវែងគ្នានឹងប្រវែងបណ្ដោយចាស់ តែឯមុមត្រឡប់ជាពុំមែនមុមកែងដូចមុនទេ ផ្ទៃនេះឈ្មោះផ្ទៃ៤ជ្រុងញាយស្រប ។

បន្ទាត់ ឃ គ គឺជាបាត (ប)

" ប ង គឺកំពស់ (ក)

មេរៀន .– ផ្ទៃញាយស្របគឺជាផ្ទៃ៤ជ្រុងមានបន្ទាត់ជ្រុងស្របគ្នាហើយប្រវែងគ្នាពីរៗ តែមុមពុំមែនជាមុមកែង ។

–នឹងរកផ្ទៃ ត្រូវយកបាតគុណនឹងកំពស់

$ម^{២} = ប \times ក$

ការហាត់ .- ឲ្យសិស្សគូសផ្ទៃ៤ជ្រុងទ្នាយស្រប១ បាតប្រវែង៩ សម កំពស់ប្រវែង៤ សម ។

ចំណោទ .- ស្រែមួយរាងជា៤ជ្រុងទ្នាយស្រប បាតប្រវែង៤៨ម,៤០កំពស់២៧ម,៥០ តើស្រែនេះឲ្យផលជាស្រូវប៉ុន្មានក្នុងមួយឆ្នាំ បើគេដឹងថាដីមួយហិកតាឲ្យផល ១.៩០០គីឡូក្រាម ។

# អាជិកម្ម

ជំពូក ១

## អាទិត្យទី១ .- លេខគុណ

បើខ្ញុំទិញដងប៉ាកកា ៣ មួយថ្លៃ ៥ សេន នោះខ្ញុំនឹងចេញថ្លៃឲ្យគេយ៉ាងដូច្នេះ ។

៥ សេន + ៥ សេន + ៥ សេន = ១៥ សេន

គឺថាថ្លៃចំនួនទាំង ៣ ដងនេះស្មើគ្នាទាំងអស់ ឬខ្ញុំត្រូវធ្វើលេខគុណដូច្នេះវិញ ។ ខ្ញុំសរសេរ ៥ សេន × ៣ = ១៥ សេន ។ ៥ ជាលេខ

តាំង ដែលខ្ញុំថាដដែលៗឡើងវិញបីដង ។ ៣ជាមេគុណ ។ លេខតាំងគឺចំនួនដែលគេហៅដដែល ៗ ឡើងវិញ ។ មេគុណគឺចំនួនប៉ុន្មានដងដែលគេថាដដែល ៗ ឡើងវិញ ។ ផលគឺជាចំនួនសរុបលេខគុណនោះ ។

លេខតាំង × មេគុណ = ផល

សេចក្ដីសំខាន់ ._ការដែលមានប្រយោជន៍ជាទីបំផុតក្នុងលេខគុណ ត្រូវឲ្យរៀនចេះចាំស្ទាត់នៃមេលេខគុណ ។

វិធីហាត់គិតមាត់ទទេ .–១– សូមសាបច្រៀងមេលេខគុណតាំងពីមេពីរឡើងវិញ រហូតមកដល់មេដប់ ។ ២– តែងមួយថ្ងៃ ៨ សេន តែង ៦ ថ្ងៃប៉ុន្មាន? ។ តែង ៨ ថ្ងៃប៉ុន្មាន? ។ តែង ៤ ថ្ងៃប៉ុន្មាន? ។ តែង ៩ ថ្ងៃប៉ុន្មាន? ។ តែង ៧ ថ្ងៃប៉ុន្មាន? ។ តែង ១០ ថ្ងៃប៉ុន្មាន? ។ ខ្ញុំពប់តើត្រូវជាប៉ុន្មាន ម្ជុល ៥ ប្រាំបួនដង ឡេវអាវ ៨ ប្រាំបួនដង កន្ត្រៃ ៤ ប្រាំបួនដង ហុងអម្បោះ ៩ ដប់ដង? ។

វិធីហាត់សរសេរ .– ១ –អ្នកជំនួញគុះទូតាំងម្នាក់ទិញកៅអី ៣៧ ថ្លៃ ៤ រៀលមួយ អ្នកនោះលក់តាំងអស់ទៅចំណេញបាន ៣២ រៀល តើថ្លៃលក់កៅអីទាំងអស់នោះប៉ុន្មាន? ។ ២–សួនមួយកង ៤ ជ្រុង បណ្ដាយ

១៨ម៉ែត្រ ទទឹង ១២ម៉ែត្រ ជុំវិញសួននោះគេធ្វើរបងថ្លៃ ១៧ សេន ១ម៉ែត្រ តើថ្លៃរបងនោះប៉ុន្មានរៀល? ។

## ២ – មេគុណមានលេខតែមួយខ្ទង់

ជាងម្នាក់មានប្រាក់ខែ ២៣ រៀលក្នុង ១ ខែ បានប្រាក់ប៉ុន្មានបើជាងនោះធ្វើការបាន ៣ ខែ ។ ក្នុង ៣ ខែជាងនោះបំណេញ ២៣ រៀល ៣ ដង ឬ ២៣ ៛, × ៣ ។ នឹងធ្វើលេខគុណបែបដូច្នេះគេត្រូវដាក់បែបនេះ៖

$$\begin{array}{r} ២៣ \\ \times ៣ \\ \hline ៦៩ \end{array}$$

គេថា ៣ បីដង៩ ខ្ញុំសរសេរ ៩ រួចខ្ញុំថា ៣ ពីរដង៦ ខ្ញុំសរសេរ៦ខាងក្រោមផលលេខនេះគឺ៦៩រៀល ។

**វិធីហាត់មាត់ទទេ .–** ចូរធ្វើលេខដូចមានដាក់ពាយមកខាងក្រោមនេះ៖

៣៣៛ × ៤ + ៦៥៛ = ... ៦២ស × ៨ : ៨ស = ...

៥៤ក × ៧ – ៧៥ក = ។ ៧៤ម × ៣ – ៥៧៩ម = .... ។

បំណោទ.– អ្នកជំនួញសត្វពាហនៈម្នាក់បានលក់ក្របី៤ថ្លៃ៤២រៀលមួយ ឃើញចំណេញទាំងអស់៤៨រៀល តើថ្លៃដើមក្របីទាំង៤នេះប៉ុន្មាន? ។

– អ្នកជំនួញសំពត់ម្នាក់បានទទួលសំពត់៥ផាប់ប្រវែង ១២ម៉ែត្រមួយផាប់រឺង៣ដុំទៀតប្រវែង១០ម៉ែត្រមួយដុំ ។ អ្នកជំនួញនោះបានទទួលសំពត់ទាំងអស់ប៉ុន្មានម៉ែត្រ? ។

## លេខគុណមានត្រាទុក

ខ្ញុំបានជួលមនុស្ស៣នាក់ធ្វើការ ហើយខ្ញុំឲ្យឈ្នួល៣៥សេនម្នាក់ៗ តើខ្ញុំត្រូវឲ្យឈ្នួលប៉ុន្មានទាំង៣នាក់នេះ? ។

ខ្ញុំសរសេរយ៉ាងនេះៈ

```
 ៣៥
×៣
----
១០៥
```

ខ្ញុំថា៣ប្រាំដង១៥ឬ៥សេនខ្ញុំសរសេរ៥រឺងប្រាក់កាក់មួយដប់សេនឬ ១០សេនមួយដង ហេតុនេះខ្ញុំត្រូវត្រាទុកមួយ ។ កាក់បីៗដង៩កាក់ហើយនឹងត្រាទុក១នោះត្រូវជា១០ខ្ញុំសរសេរដប់គឺ ១០៥សេន ខ្ញុំត្រូវឲ្យឈ្នួលទាំង-អស់១០៥សេន ។

វិធីហាត់សរសេរ .– ហេតុអ្វីនៅក្នុងលេខគុណមានត្រាទុក គេត្រូវផ្ដើមគុណពីខាងស្ដាំមិនឲ្យផ្ដើមគុណពីឆ្វេង ? លេខត្រាទុកមានហួសពីលេខ ៨ ឬទេ ? ហេតុអ្វី ? អ្នកត្រូវរកយ៉ាងដូចម្ដេចឲ្យបានឆាប់ឃើញថ្លៃគោ ៣ ទឹមនឹងថ្លៃគោ ២ ទឹមបើគោមួយថ្លៃ៤៧រៀល ? ។

វិធីហាត់សរសេរ .– ១-ចូរធ្វើលេខដូចមានខាងក្រោមនេះ ៖

៥៦រ × ៦ =　　៧៥រ × ៧ =　　៩៨រ × ៨ =

៣៩២ម × ៣ =　　៧២៤ម × ៥ =　　៦៥៩ល × ៤ =

អាទិត្យទី ២ .– លេខចែក ( ផើងហារមានលេខតែមួយតួ )

ខ្ញុំចង់ចែកស្លាបប៉ាកកា ២៤ ឲ្យសិស្ស ៤ នាក់ តើម្នាក់ត្រូវបានប៉ុន្មាន ? ។ រកចំណែកម្នាក់ ៗ នោះត្រូវយកចំនួន ២៤ មកចែកនឹង ៤ ។ យើងគិតថា ក្នុង ២៤ តើមាន ៤ ប៉ុន្មានដង ? ថាមាន៤ប្រាំមួយដង, ដូច្នេះសិស្សម្នាក់ៗ ត្រូវបានស្លាបប៉ាកកា ៦ ។ គេសរសេរលេខយ៉ាងនេះ ២៤:៤=៦ ហើយ ដើម្បីនឹងធ្វើលេខចែកយ៉ាងនេះដោយងាយ នោះត្រូវរៀនមេលេខឲ្យស្ទាត់ ។

សូមមើលហើយបង្រៀនតាមសៀវភៅក្បួននព្វន្តទំព័រទី២៣ ដល់ ៤៧ ។

## អាទិត្យទី៣ .–១.– ថ្លៃទិញវត្ថុសរុប

ឧបមា: មាខ្ញុំលក់ទោចក្រយានមួយ ថ្លៃ ៧៣៥៛, គាត់បានចំណេញទាំងអស់ ១៣៥៛, តើទោចក្រយាននោះទិញមកថ្លៃប៉ុន្មាន? ។

នឹងរកថ្លៃទិញវត្ថុសរុបអ្វីមួយត្រូវយកប្រាក់ចំណេញទៅកាត់ថ្លៃលក់ចេញ គឺ:

៧៣៥៛, – ១៣៥៛, ( លក់ – ចំណេញ )

ឃើញថាទោចក្រយាននោះទិញមកថ្លៃ ៦០០៛, ។

**វិធីហាត់គិតមាត់ទទេ .–** អ្នកស្រែម្នាក់លក់ចៀមមួយថ្លៃ ២៨៣ រៀល ហើយបានចំណេញ ៥០ រៀល តើចៀមនោះទិញមកថ្លៃប៉ុន្មាន? ។

ស្រីម្នាក់លក់ក្រមា ៥ ថ្លៃ ៤៣ រៀល ហើយបានចំណេញ ១៣ រៀល តើក្រមាទាំងអស់ទិញមកថ្លៃប៉ុន្មាន?

**វិធីហាត់សរសេរ .–ចំណោទ.–** ឪពុកខ្ញុំលក់មួក ៥ បានថ្លៃ ១៣៣ រៀល មួកមួយ ហើយបានចំណេញទាំងអស់ ១២៥៛, ។ តើមួកទាំងអស់ទិញមកថ្លៃប៉ុន្មាន? ។

### ២.– ថ្លៃទិញរបស់និមួយៗ

ឧបមា: ឈ្មួញម្នាក់លក់ទូ ៣ ថ្លៃទាំងអស់ ៣៥០៛, ហើយបានចំណេញ

៥០រ, តើថ្លៃដើមខ្ទះមួយទិញមកថ្លៃប៉ុន្មាន ? មុនដំបូងរកថ្លៃដើមខ្ទះមួយៗ ត្រូវរកថ្លៃដើមខ្ទះទាំង៣ សិន ទើបយកថ្លៃដើមខ្ទះទាំងអស់មកចែកនឹងចំនួនខ្ទះនោះគឺ:

ថ្លៃដើមខ្ទះទាំង ៣ គឺ: (ថ្លៃលក់-ចំណេញ)

៣៥០រ,-៥០រ,= ៣០០រ,

ថ្លៃដើមខ្ទះមួយ: (ថ្លៃដើម:ចំនួនរបស់ដែលទិញមក)

៣០០រ, : ៣ = ១០០រ,

ឆ្លើយថាខ្ទះមួយ ៗ ទិញមកថ្លៃ ១០០រ,

វិធីហាត់គិតមាត់ទទេ .— ១– ស្រីម្នាក់លក់មាន់៣ថ្លៃ ៣៣រៀល ហើយបានចំណេញ ៩ រៀល, តើមាន់មួយទិញមកថ្លៃប៉ុន្មាន? ។

២- ចិនម្នាក់លក់ស្រាទំពាំងបាយជូរ ៥ ដបថ្លៃ ៥៥រ, ហើយចំណេញ ១៥ រៀល តើស្រាទំពាំងបាយជូរមួយដបទិញមកថ្លៃប៉ុន្មាន? ។

វិធីហាត់សរសេរ .— លំហាត់ — យួនម្នាក់លក់មួកស្លឹក៣ ឡូថ្លៃ ២២៦ រៀល បានចំណេញ ៣៦ រៀល ។ តើមួកនីមួយៗ ទិញមកថ្លៃប៉ុន្មាន? ។

# វង្វាស់វង្វាល់

**អាទិត្យទី ១.–** អំពីក្រដាសប្រាក់សំរាប់ចាយនៅប្រទេសឥណ្ឌូចិនៈ ប្រាក់ក្រដាសមួយរៀល, ៥ រៀល ។

សូមយកប្រាក់ក្រដាសមកបង្រៀន ហើយឲ្យបានច្រើនយ៉ាងផង គឺក្រដាសជាន់ចាស់និងក្រដាសប្រាក់ជាន់ថ្មី ៗ បង្ហាញក្រដាសប្រាក់ ១ រៀលឲ្យសិស្សមើល នេះក្រដាសប្រាក់ ១ រៀលមានសរសេរលេខចំនួន ១ រៀលជាប់នៅនេះផង ដើម្បីកុំឲ្យច្រឡំ មានពណ៌ក្បាច់រចនាក៏ស្អាតហើយមានរូបយួនប្រុសស្រីទៀតផង ។ ក្រដាសប្រាក់ ១ រៀលជាន់ថ្មី ខុសពីក្រដាសប្រាក់ ១ រៀលជាន់ចាស់ដោយទំហំនិងគំនូរ ៗ ក្រដាសប្រាក់ប្រាំរៀលជាន់ថ្មីមានរូបប្រាសាទខុសអំពីក្រដាសចាស់ដែលមានរូបគោក ។ល។ ក្រដាសប្រាក់ស្រាលគេយកទៅណាមកណាបានដោយងាយដល់អ្នកដំនួញទាំងឡាយ ប៉ុន្តែត្រូវប្រយ័ត្នក្រដាសប្រាក់ក្លែងក្លាយ គេចំណាំនិងលេខនិងសាច់ក្រដាសឬនិងពណ៌ក្រដាស ។ល។

**ហាត់គិតមាត់ទទេ .–** ក្រៅពីប្រាក់រៀល ឬប្រាក់កាក់មានប្រាក់អ្វីខ្លះសំរាប់ចាយនៅស្រុកយើង ? ប្រាក់ក្រដាសមួយរៀលពណ៌ដូចម្ដេច ? មានរូប

អ្វី ? ប្រាក់ក្រដាស ១ រៀល នឹង ៥ រៀល ដូចគ្នាឬទេ ? ខុសគ្នានឹងអ្វី ? ឯង មើលពីចម្ងាយស្គាល់ជាក្រដាស ១ រៀល ៥ រៀលឬទេ ? ពីព្រោះអ្វី បានជាគេយកក្រដាសធ្វើជាប្រាក់ចាយ ៗ ក្នុងប្រាក់ក្រដាស ១ រៀល នឹងប្រាក់សាច់ ១ រៀល ប្រាក់ណាមានដំឡៃជាង ? ពីព្រោះអ្វីបានជា មានដំឡៃដូចគ្នា ? ក្នុងប្រាក់ក្រដាស ១ រៀល មានប៉ុន្មានកាក់ ? ៗលៗ

ហាត់គិតនឹងក្តារខ្មៀន.— ត្រូវជាប៉ុន្មាន ២៥ នឹង ៣៨ រៀល ? ១០៧', នឹង ៨០ រៀល ? ប្រាក់ក្រដាស ៥ រៀល ៣ សន្លឹក នឹងក្រដាស ១ រៀល ២៦ សន្លឹក ត្រូវជាប៉ុន្មានរៀល ? ៗលៗ

អាទិត្យទី ២.— ប្រាក់ក្រដាស ២០ រៀល ១០០ រៀល ៗ

សូមធ្វើដូចអាទិត្យទី ១ ខាងលើនេះ ពន្យល់សិស្សអំពីពណ៌ទំហំ ក្រដាសប្រាក់ ថ្លៃរៀលនឹង ១០០ រៀល ឲ្យស្គាល់ប្រាកដ ៗ

ហាត់គិតមាត់ទទេ .— ក្រដាសប្រាក់មានប៉ុន្មានយ៉ាង ? ក្រដាសប្រាក់អ្វីខ្លះ ? ក្រដាសប្រាក់ទាំងនេះដូចគ្នាឬទេ ? ខុសគ្នានឹងអ្វី ? ៗលៗ

ហាត់គិតនឹងក្តារខ្មៀន .— ត្រូវជាប៉ុន្មានរៀល ២៧ រៀល នឹង ៣៣ រៀល ? ១៧៥', នឹង ១៤០ រៀល ? ១៩០', នឹង ១០០ រៀល, ៗលៗ

នៅសល់ប៉ុន្មាន ២៨០៛, កាត់ ១៩០ រៀលចេញ ? ៣៥០ រៀលដក ១៨៥ រៀលចេញ ? ខ្ចីគេម្ដង ១៥០ រៀលម្ដងទៀត ៩៥ រៀល តើជំពាក់គេទាំងអស់ប៉ុន្មានរៀល ? បងខ្ញុំជំពាក់គេ២៨០ រៀលយក ១៩៥ រៀលទៅសងគេ តើបងខ្ញុំនៅជំពាក់គេប៉ុន្មានរៀលទៀត ។ ល ។

ហាត់សរសេរ .– ១- ចូរធ្វើលេខដូចមានខាងក្រោមនេះ ៖

២០១៛,+១៩៧៛,=...រៀល ។ ៣៥០៛,+១៥៥៛,=...រៀល ។

៣៦៧៛,-២៧២៛,=...រៀល ។ ៤៥២៛,-២០៧៛,=...រៀល ។

២– បងទោនាងទិញបង្កៀង ១ ថ្លៃ ១៦ រៀល ទិញម៉ាស៊ីនច្រៀង ១ ថ្លៃ ៥៤ រៀល រួចបានឲ្យក្រដាស ១០០ រៀលមួយសន្លឹកទៅអ្នកលក់ ។ ត្រូវថែមឲ្យមកវិញ....រៀល ។

## អាទិត្យទី ៣ .– អំពីប្រាក់ណែន

សូមរកប្រាក់ណែនមកឲ្យសិស្សមើល បើគ្មានត្រូវគូរនៅក្ដារខៀន ។ ប្រាក់ណែនរាងដូចស្លាបឥតមានក្បាច់អ្វីទេងាយនឹងធ្វើណាស់ ។ ក្នុង ១ ណែនមានទម្ងន់ ១៦ រៀល ហេតុនេះបានជាគេចាយ ១៦ រៀល ។ ឥឡូវនេះរាជការលែងឲ្យចាយប្រាក់ណែននឹងប្រាក់ជាន់ចាស់ហើយ ពីព្រោះប្រាក់ទាំងនេះមនុស្សខូចកាចធ្វើក្លែងក្លាយបានដោយងាយណាស់ ។

ហាត់សរសេរ .– មាខ្ញុំលក់ស្រូវបាន៤ណែន លក់គោគបាន១២០រៀល មាខ្ញុំបានប្រាក់ទាំងអស់......រៀល ។

# មធ្យមដ្ឋានទី១

## នព្វន្ត

### អាទិត្យទី ១ .– ចំនួនពីមួយពាន់ទៅដល់មួយម៉ឺន

ឯរបៀបរាប់ចំនួនពី ១.០០០ ទៅដល់ ១០.០០០ ក៏ដូចជារាប់ចំនួនពី ១០០ដល់ ១.០០០ដែរ គេរាប់ថាមួយពាន់មួយ មួពាន់ពីរ មួយពាន់បី តរៀងៗទៅដល់ ១.០៩៩ ទើបគេថាមួយពាន់មួយរយ រួចទើបគេរាប់ពីមួយពាន់មួយរយតទៅ មួយពាន់ពីររយ មួយពាន់បីរយរហូតតទៅដល់មួយម៉ឺន (១០.០០០) ។ ឯចំនួនពី១ដល់៩ លេខមានតែមួយតួគឺចំនួនរាយឬខ្ទង់រាយ ។ ពី១០ដល់៩៩ មានលេខពីរតួគឺខ្ទង់ដប់ ។ ១០០ដល់៩៩៩ មានលេខបីតួគឺខ្ទង់រយ ។ ពី១.០០០ដល់ ៩៩៩៩ មានលេខបួនតួគឺខ្ទង់ពាន់ ។ ១០.០០០ដល់ ៩៩.៩៩៩ មានលេខប្រាំតួគឺខ្ទង់ម៉ឺន ។

ដូចមានតារាងដាក់ឈ្មោះខ្ទង់ខាងក្រោមស្រាប់

| ខ្ទង់ម៉ឺន | ខ្ទង់ពាន់ | ខ្ទង់រយ | ខ្ទង់ដប់ | ខ្ទង់កាយ |
|---|---|---|---|---|
| ៩ | ៤ | ៧ | ៩ | ២ |

របៀបរៀនមើល .- ទីងរៀនមើលលេខនេះ គេចាប់មើលពីឆ្វេងទៅស្តាំ ឧបមាដូចជា៩៤៧៩២ គេមើលថាប្រាំបួនម៉ឺនបួនពាន់ប្រាំពីររយកៅសិបពីរ ពីព្រោះ៩នៅខ្ទង់ម៉ឺន រួចគេមើលលេខបន្ទាប់ ៤ ពាន់ពីព្រោះលេខ៤នៅក្នុងខ្ទង់ពាន់ ហើយមើលលេខតមកទៀត៧រយ ពីព្រោះលេខ៧នៅខ្ទង់រយ ហើយគេមើលមកទៀតកៅសិប ពីព្រោះលេខ៩នៅខ្ទង់សិប ហើគេមើលលេខចុងក្រោយបំផុតថាពីរ ពីព្រោះលេខពីរនៅខ្ទង់ទីងឬកាយ ។

របៀបរៀនសរសេរ .- ទីងសរសេរចំនួនដល់ម៉ឺននេះ ក៏ដូចជាគេសរសេរចំនួនពី ១ ដល់ ១.០០០ដែរ គេចាប់សរសេរពីឆ្វេងទៅស្តាំ គឺចាប់ពីខ្ទង់ម៉ឺនមកខ្ទង់ពាន់ មកខ្ទង់រយ មកខ្ទង់សិប រួចមកខ្ទង់ទីង ប៉ុន្តែបើចំនួនណាមួយខ្វះ ក្នុងខ្ទង់ម៉ឺនក្តី ខ្ទង់ពាន់ក្តី ខ្ទង់រយក្តី ។ល។ គេដាក់លេខសូន្យជំនួស ឧបមាដូចជា១៤០៩១ ។

ហាត់គិតមាត់ទទេ .— ហៅចំនួនឲ្យសិស្សសរសេរនៅលើក្ដារខៀន ១៥.៩៧២ ។ ១៩.៥៦៣ ។ ៧.៨៩៧ ។ល។ ឲ្យសិស្សមើលសូត្រចំនួនខាងក្រោមនេះ ៩៥.៧៥១ ។ ២.៣៥៦ ។ ៣៧.៤៦១ ។ ៩៥.៦៨៩ ចូរឲ្យសិស្សរាប់បន្ថែមមួយរយ ៗ ពី ១០០ ទៅដល់ ១០.០០០ ។

វិធីហាត់គិតនឹងក្ដារខៀន .— ត្រូវជាប៉ុន្មាន ? ១៥.០០០ នឹង ២៣.៤០០ ។ ១៣.០០០នឹង ៧០.០០០ ។ ៤៩.០០០ នឹង ៦.០០០ ។ ១៣.០០០ ដក ៥.០០០ ចេញ ។ ២— ខ្ញុំថា ៣៤.០០០ នឹង ៣.០០០ គឺ ៤ នឹង ៣ បានជា ៣៧.០០០ ។ ខ្ញុំគិតតន្ទួនបែបដូចគ្នាទៅទៀត ។ ៣៦.០០០ នឹង ២.០០០ ។ ៧៣.០០០ នឹង ៥.០០០ ៦៤.០០០ ដក ៣.០០០ ចេញ ។

វិធីហាត់សរសេរ-បំណោទ .— ១— ក្នុងការសង់ផ្ទះមួយគេបានដឹកឥដ្ឋ ៥ រទេះ ក្នុងមួយរទេះមានឥដ្ឋ ១.០០០ដុំ រួចគេបានប្រើឥដ្ឋនោះអស់ ៣ ០០០ ដុំ តើគេនៅសល់ឥដ្ឋប៉ុន្មានដុំទៀត ?

២- អ្នកម៉ៅការម្នាក់បានទិញដីមួយកន្លែងថ្លៃ ១៥៤០ រៀល អ្នកនោះបានសង់ផ្ទះ ១ នៅនាដីនោះថ្លៃ ៥៤៨៧ រៀល ដល់លក់ផ្ទះទៅវិញបានថ្លៃ ៨.៩០០រៀល តើអ្នកនោះបានចំណេញប៉ុន្មាន ?

### អាទិត្យទី ២.— លេខគុណនឹង ១០-១០០-១.០០០

តុមួយថ្លៃ ៥ រៀល បើតុ ១០ ថ្លៃប៉ុន្មាន ? យើងដឹងថាតុ ១ ថ្លៃ ៥ រៀល បើតុដប់យ៉ាងដូច្នេះថ្លៃ ៥ រៀលដប់ដងទៅទៀត គឺថា ៥ ដប់ដង ត្រូវជា ៥០ ។ ក៏ប៉ុន្តែយើងគុណលេខចំនួនប៉ុន្មាន ៗ ក្តីនឹង ១០ – ១០០ – ១.០០០ នេះគេមិនចាំបាច់ធ្វើលេខដូចធម្មតាទេ គ្រាន់តែថែមសូន្យមួយនៅខាងស្តាំចំនួននោះ បើគុណនឹង ១០ ។ សូន្យពីរបើគុណនឹង ១០០ ។ សូន្យបី បើគុណនឹង ១.០០០ ។

### អាទិត្យទី ៣.— លេខចែកនឹង ១០ – ១០០ – ១.០០០

តុដប់ថ្លៃ ៦០ រៀល តើតុមួយថ្លៃប៉ុន្មាន ។ យើងដឹងថាតុដប់ថ្លៃ ៦០ រៀល បើតុមួយថ្លៃតិចជាងគឺយ៉ាងដូច្នេះ ៦០រ,:១០ = ៦ រៀល ។ ក៏ប៉ុន្តែនឹងចែកលេខចំនួនប៉ុន្មាន ៗ ក្តីនឹង ១០ – ១០០ – ១.០០០ នេះ គេមិនចាំបាច់ធ្វើលេខដូចធម្មតាទេ គេគ្រាន់តែបន្ទយកណ្តក់សញ្ញាពីខាងស្តាំទៅខាងឆ្វេងមួយខ្ទង់ សំរាប់ចែកនឹង ១០ ។ ពីរខ្ទង់សំរាប់ចែកនឹង ១០០ ។ បីខ្ទង់សំរាប់ចែកនឹង ១.០០០ ។ល។ ឧបមាដូចជាលេខ ៨.៩២០ ចែកនឹង ១០ ត្រូវបាន ៨៩២,០ ។ ៨.៩២០ ចែកនឹង ១០០ ត្រូវបាន ៨៩,២០ ។ ៨.៩២០ ចែកនឹង ១០០០ ត្រូវបាន ៨,៩២០ ។ល។

មេរៀនឲ្យចាំមាត់.– បើកាលណាត្រូវចែកចំនួនអ្វីនីមួយៗ នឹង ១០. ១០០ – ១,០០០ នោះ គេមិនបាច់ធ្វើលេខទេ គេត្រូវតែបន្ថយកណ្តក់សញ្ញាពីស្តាំទៅឆ្វេងមួយខ្ទង់ពីរខ្ទង់បីខ្ទង់ ។ល។

## រង្វាស់រង្វាល់

### អាទិត្យ ១.– ដេស៊ីម៉ែត្រ

សូមពិនិត្យម៉ែត្រឲ្យឃើញថាម៉ែត្រនោះចែកជា ១០ កំណាត់ស្មើគ្នា មួយកំណាត់ ហៅថាមួយដេស៊ីម៉ែត្រ ឬមួយភាគដប់នៃម៉ែត្រ មួយដេស៊ីម៉ែត្រ គឺមួយភាគដប់តូចជាងម៉ែត្រ ។

មួយម៉ែត្រមាន ១០ ដេស៊ីម៉ែត្រ គេសរសេរកាត់ ដ.ម. ឧបមាដូចជា ៦៥ម – ៦៥០ ដ.ម. ។ ៩០ ដ.ម. = ៩ ម ឧបមាវាស់បណ្តោយវត្ថុមួយ គេឃើញ ២ ម៉ែត្រ ៧ ដេស៊ីម៉ែត្រ ឬ ២ ម៉ែត្រនឹង ៧ ភាគដប់ម៉ែត្រ គេសរសេរ ២ម,៧ ។

គេវាស់បណ្តោយវត្ថុមួយទៀត ឃើញ ៤ ដេស៊ីម៉ែត្រភាគដប់ម៉ែត្រ គេសរសេរ ០,៤០, ៧ នឹង ០,៤ ហៅថាចំនួនបែរភាគគត់ ៧ ភាគដប់នឹង ៤ ភាគដប់ ហៅចំណែកបែងភាគគត់ពីមួយចំនួនណា គ្មានចំណែកបែង

ភាគតត់ហៅថាចំនួនដុំ ចំនួនបែងភាគតត់តែងមានចំណែកបែងភាគតត់ពីមួយជាដរាប ។

ពាក្យសួរ ៖— ១–មួយម៉ែត្រមានប៉ុន្មានដេស៊ីម៉ែត្រ ?

២- មួយដេស៊ីម៉ែត្រ គឺជាភាគប៉ុន្មានពីម៉ែត្រ ?

៣- យ៉ាងដូចម្ដេចហៅថាចំនួនដុំ ?

៤- យ៉ាងដូចម្ដេច ហៅថា ចំនួនបែងភាគតត់ ?

៥- ចំនួនបែងភាគតត់មានប៉ុន្មានចំណែក ?

៦- ក្នុងចំនួនបែងភាគតត់ លេខខ្ទង់ដើមខាងស្ដាំគេដាក់សញ្ញាហៅអ្វី ?

វិធីហាត់សរសេរ ៖—ចូររកចំនួនខាងក្រោមនេះ ៖

៣២ម + ៥៧ម = ...ដម ។ ១៦២០ម : ១០ = ...ដម ។ ១៨៧ដម + ៤៩ = ...ដម ។ ២២៤ × ដម ៥ = ...ដម = ... ម ។ ១៣ដម × ៣០ម × ៥ដម = ..ម...ដម ។

## អាទិត្យទី២ ៖— ដេស៊ីលីត្រ

រង្វាល់ចំណុះចំនួនគត់គឺលីត្រ រង្វាល់លីត្រមួយ យើងអាចវាល់ចំណុះដបស្រាទំពាំងបាយជូរមួយបានឬទេ? ដបទឹកក្រូចមួយបានឬទេ ? ហេតុ

អ្វីបានជាវាល់មិនបាន ។ ដើម្បីនឹងវាស់ប្រវែងខ្លីៗជាងម៉ែត្រ នោះគេបានក្រិតចែកម៉ែត្រនោះជាដេស៊ីម៉ែត្រ ហើយហៅដូច្នេះគឺថាដូចគ្នាដែរ នឹងវាល់ចំណុះវត្ថុអ្វីមួយៗ ដែលតូចជាងលីត្រនោះគេបានធ្វើរង្វាល់តូចជាងលីត្រ គឺដេស៊ីលីត្រ ។ គេសរសេរកាត់: ១ ដ.ល. ។ ដេស៊ីលីត្រគឺ១ភាគដប់តូចជាងលីត្រ ហេតុដូច្នេះមួយលីត្រមានដប់ដេស៊ីលីត្រ (១០ ដល) ។

សូមត្រួតត្រាផ្ទៀងមើល នឹងលីត្រហើយនឹងដេស៊ីលីត្រ ។ វាល់នឹងដេស៊ីលីត្រហើយចាក់ទៅក្នុងលីត្រ ។

**វិធីហាត់គិតមាត់ទទេ** ៖— មានប៉ុន្មានដេស៊ីលីត្រក្នុង២ លីត្រ? ៥លីត្រ? ៣លីត្រ។ ១លីត្រកន្លះ? ៣លីត្រកន្លះ? ។ ដបមួយមានចំណុះស្រាមួយលីត្រ គេបានលក់អស់៥ ដ.ល នៅសល់ស្រាប៉ុន្មានដេស៊ីលីត្រទៀតក្នុងដបនោះ? ។ រួចគេលក់ម្ដងទៀតអស់៣ ដ. ល ក្នុងដបស្រានោះនៅប៉ុន្មានដេស៊ីលីត្រទៀត? ។ ដែលនឹងបំពេញដបមួយមានចំណុះមួយលីត្រ គេត្រូវចាក់ថែមប៉ុន្មានទៀតទៅក្នុងដបនោះ បើសិនជានៅក្នុងដបនោះមាន២ ដ.ល? ។ ៥ ដ.ល. ។ ៨ដ.ល. ។ ១ដ.ល. ។ ៧ ដ.ល. ។ ៦ដ.ល ។ ៩ដ.ល. ។ ២ ដ.ល. ។ ៤ ដ.ល. ។

បំណោទ ៖– ធុងទឹកមួយមានស្រាចំណុះ៥ល ៨ គេដងស្រានោះមុនដំបូង ២ល. រួច១ល ៦ ហើយគេចាក់ចូលទៅវិញ១ល៩ ។ មានស្រាប៉ុន្មានលីត្រទៀតនៅក្នុងធុងនោះ ? ។

**អាទិត្យទី៣ –** **ជើងក្រាម**

សូមបង្រៀនដូចរបៀបខាងលើនេះ ។

# មជ្ឈិមដ្ឋាន និង អាជិកដ្ឋាន

## ធរណីមាត្រសាស្ត្រ

**អាទិត្យទី ១ –** អំពីមុំ. មុំផ្សេង ៗ –

**ប្រដាប់បង្រៀន –** ប្រដាប់ឈាន (កំប៉ា)

**អត្ថន័យ –**




បន្ទាត់ ខ.ក. នឹងបន្ទាត់ ខ.គ. ដែលចេញពីចំណុចតែមួយបង្កើតជាមុំមួយ គឺមុំ ក.ខ.គ. ។

បន្ទាត់ ខ.ក នឹង ខ.គ. ជាជ្រុងរបស់មុំ ។ ចំណុច ខ. ជាកំពូលរបស់មុំ ។

មុមផ្សេងៗ ១.— មុមកែង — មុមកែងកើតពីជ្រុងសំយុងត្រង់លើគ្នា ។

២ — មុមស្រួច — តូចជាងមុមកែង ។

៣ — មុមញាយ — ធំជាងមុមកែង ។

សេចក្ដីរំលឹក — មុមតូចធំមិនមែនស្រេចនឹងប្រវែងជ្រុងឡើយគឺស្រេចនឹងវង្វះជ្រុងដែលឃ្លាតពីគ្នា ។ សូមគ្រូយកប្រដាប់ឈានពីរ ទំហំខុសគ្នាមកធ្វើពិសោធន៍ឲ្យសិស្សមើល ។ ហើយឲ្យសិស្សនេះហៅឈ្មោះមុមដោយហៅអក្សរកំពូលនៅកណ្ដាលជានិច្ច ។

អាទិត្យទី ២.— បួនជ្រុងស្មើ - បន្ទាត់អឡ្យបាត (មេឌីយ៉ាន) - បន្ទាត់ទ្រូង (ឌីយ៉ាគោណាល់)

ប្រដាប់បង្រៀន.— ក្រដាសបួនជ្រុងស្មើដើម្បីបត់បង្ហាញសិស្សឲ្យឃើញថា ៖

ក.— ក្នុងបួនជ្រុងស្មើបន្ទាត់អឡ្យបាតនឹងបន្ទាត់ទ្រូងកាត់គ្នាចំពាក់កណ្ដាល ។

១.— ហើយមុមដែលកើតឡើងជាមុមកែង ។

អាទិត្យទី ៣— បរិវេណនៃបួនជ្រុងស្មើ ។

អាទិត្យទី ៤ .— រកប្រវែងជ្រុងមួយក្នុងបួនជ្រុងស្មើ ។

សូមគ្រូចាត់ចែងបង្រៀនផងចុះ ។

# បរិទដ្ឋណាដ្ឋាន

ឥព្ទ ១

មេរៀនទី ១ .— ចំនួន ១៩៩ ដល់ ២៩៩

ការរៀនកប់ .— រៀនមើល-រៀនសរសេរចំនួននឹងការហាត់គិត ។

សូមធ្វើតាមរបៀបបង្រៀនចំនួនពី ១០០ ដល់ ១១៩ ដែលមានជាគំរូស្រាប់នៅក្នុងទស្សនាវដ្ដីឆ្នាំទី ២ លេខ ២ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី ២ .— ចំនួនពី ១៩៩ ដល់ ២៩៩

បង្រៀនធ្វើលេខបូកទាំងលេខសងឥតត្រាទុកនឹងមានត្រាទុក ។

មេរៀនទី ៣ .— ចំនួនពី ២៩៩ ដល់ ៣៩៩

ការរៀនកប់ - រៀនមើល - រៀនសរសេរចំនួន នឹងការហាត់គិត ។

មេរៀនទី ៤ .– ចំនួនពី ២៩៩ ដល់ ៣៩៩

បង្រៀនធ្វើលេខគុណ - គុណចំនួននឹង ៣ - ៤ - ៥ . ។

មេរៀនទី ៥ .– ចំនួនពី ៣៩៩ ដល់ ៤៩៩

ការរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន និងការហាត់គិត ។

មេរៀនទី ៦ .– ចំនួនដល់ ៤៩៩

បង្រៀនចែកចំនួននឹង ៣ - ៤ - ៥ ។

មេរៀនទី ៧ .– សាបញ្ជាក់ចំនួនពី ១០០ ដល់ ៤៩៩

ការហាត់គិត - រៀនរាប់ - រៀនមើល - រៀនសរសេរចំនួន ។

មេរៀនទី ៨ .– ចំនួនដល់ ៤៩៩ - សាបញ្ជាក់អំពីលេខបូក-សង-ហើយ

និងគុណ-ចែកចំនួននឹង ៣ - ៤ - ៥ - ។

សូមមើលតាមរបៀបតែងជាគំរូនៅក្នុងទស្សនាវដ្ដីឆ្នាំទី ២

លេខ ២ សព្វគ្រប់ស្រាប់ ហើយសូមតែងការហាត់ផងចុះ ។

## រង្វាស់រង្វាល់

មេរៀនទី១ – អំពីដេកាម៉ែត្រ – ច្រវាក់ដេកាម៉ែត្រ ។

របស់សំរាប់បង្រៀន.— ម៉ែត្របត់ឬបន្ទាត់ នឹងប្រវាត់ដេកាម៉ែត្រ ។

របៀបបង្រៀន.— គ្រូនាំសិស្សចេញទៅរៀននៅទីធ្លាសាលារៀនឬនៅទីវាល សិស្សម្នាក់ៗត្រូវមានក្ដារឆ្នួនមួយនឹងដីស ។

១- គ្រូនាំសិស្សវាស់ប្រវែង ១០ម នឹងរង្វាស់ម៉ែត្រឲ្យគូសចំណាំប្រវែង ១ម.

២- គ្រូនាំសិស្សវាស់ប្រវែង ១០ម នោះនឹងប្រវាត់ដេកាម៉ែត្រ ។

៣- នាំសិស្សពិនិត្យមើលប្រវាត់នោះហើយសួរសាកសិស្សថា:

ក- ប្រវាត់នេះមានប្រវែងប៉ុន្មានម៉ែត្រ ។

ខ- ក្នុងប្រវែង ១ម មានដែកប៉ុន្មានកង់ ? មានក្រវិលប៉ុន្មាន ? ក្រវិលស្ពាន់សំរាប់ចំណាំអ្វី ?

គ- ដល់មកប្រវែង ៥ម មានអ្វីជាទីសំគាល់ ?

៤- នាំសិស្សហាត់ស្ទានប្រវែង ១០ម ។ ឲ្យសិស្សស្ទានបណ្ដោយផ្លូវ ១- ឲ្យវាសរសេរបណ្ដោយនោះនៅលើក្ដារឆ្នួនហើយវាស់បញ្ជាក់ ។ ហាត់ស្ទានបែបនេះឲ្យបានច្រើន ។

៥- នាំសិស្សចូលមកក្នុងកន្លែងរៀនវិញប្រាប់សិស្សថា:

ប្រវែង ១០ ម គេហៅថា ១ ដេកាម៉ែត្រ - គ្រូសរសេរពាក្យនេះនៅលើក្ដារខៀន (សរសេរជាអក្សរកាត់ផង) ឲ្យសិស្សមើល ។

៦- សួរសាកបញ្ជាក់សិស្សឡើងវិញ អំពីច្រវាក់ដេកាម៉ែត្រនិងអំពីប្រយោជន៍ច្រវាក់នោះ ។

៧- ការហាត់បញ្ជាក់ដោយគិតមាត់ទទេ ។

៨- ការហាត់បញ្ជាក់ដោយសរសេរនៅក្នុងសៀវភៅ ។

សូមតែងការហាត់តាំងពីរបៀបខាងលើនេះផង ។

## មេរៀនទី ២.– អំពីដេកាលីត្រ

**របស់សំរាប់បង្រៀន .–** រង្វាល់លីត្រ· ដេកាលីត្រនិងរបស់សំរាប់វាល់ដូចជាទឹក ឬអង្ករ ឬដីខ្សាច់ ។

**របៀបបង្រៀន.–** ១- ការពិនិត្យរង្វាល់-ឲ្យសិស្សស្គាល់ចំណុះ ១ ដាល ហើយស្គាល់រង្វាល់ ១ ដាល.។

២- ការហាត់ស្ទាន និងវាល់ បញ្ជាក់នៃការស្ទាននោះ

៣- ការហាត់គិតមាត់ទទេបញ្ជាក់អំពីរង្វាល់ដែលបានបង្រៀននេះ

៤- ការហាត់សរសេរនៅក្នុងសៀវភៅ ។

### មេរៀនទី ៣.— អំពីកូនទម្ងន់ ១ ដេកាក្រាម

**របស់សំរាប់បង្រៀន.—** កូនទម្ងន់ ១ ដាក្រ- ជញ្ជីង នឹងរបស់សំរាប់រៀនថ្លឹងដែលមានទម្ងន់ ១ ដាក្រ- ៣ ដាក្រ- ៥ ដាក្រ ។

**របៀបបង្រៀន.—** សូមធ្វើតាមរបៀបខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

### មេរៀនទី ៤.— អំពីផ្ទៃបួនជ្រុងស្មើ

**របស់សំរាប់បង្រៀន.—** ក្រដាសកាត់ជារាងបួនជ្រុងស្មើ- គំនូរ ៤ ជ្រុងស្មើគូរនៅលើក្ដារខៀន ។

**របៀបសំរាប់បង្រៀន.—** នាំសិស្សពិនិត្យមើលក្រដាសរាងបួនជ្រុងស្មើ នឹងគំនូរដែលគូរនៅលើក្ដារខៀន- ឲ្យឃើញលក្ខណៈ:

១— ជ្រុងទាំង ៤ ប្រវែងគ្នា

២— មុំទាំង ៤ ជាមុំកែង

នាំសិស្សពិចារណារកប្រវែងជុំវិញផ្ទៃបួនជ្រុងស្មើ ។

**កាហាត់បញ្ជាក់ .—** ឲ្យសិស្សរកជុំវិញផ្ទៃរាង ៤ ជ្រុងស្មើ ១ ជ្រុង ៗ ប្រវែង ៥ម— ៧ម— ១៩ម— ៩៣ម ។

**ការហាត់សរសេរ.—** សូមតែងការហាត់នេះផងចុះ ។

# កុមារដ្ឋាន

## នព្វន្ត

បំនួនពី ២០ ដល់ ៣០ ។

បង្រៀនឲ្យរាប់ពី១ដល់ ៣០ ; បង្កើនម្តង ២ ; ម្តង ៣ ; ម្តង ៤ ; ម្តង ៥ ; ។

បង្រៀនឲ្យធ្វើលេខបូក និង លេខសង ឥតគ្រាទុក ។

## មតិសំខ្យា

មុននឹងចាប់បង្រៀន នព្វន្ត គ្រូត្រូវបង្រៀនសិស្សឲ្យគិតលេខ ដោយមតិសំខ្យា (គិតនឹងខួរក្បាល ឥតសរសេរ) ។ វិធីនេះ មានបំនួនពេលត្រឹមតែ ៥ មីនុត ហើយចំពោះតែលើចំនួន ដែលសិស្សបានរៀនពីពេលមុនរួចហើយ ។

**ឧទាហរណ៍** = ឲ្យសិស្សរាប់ពី ១ ដល់ ២០ ហើយពី ២០ ចុះមក ១ វិញ បង្កើន ឬ បន្ថយ ម្តង ១ ២

ក)= ពី ១ ដល់ ២០ បង្កើនម្តង ២.

៣ ; ៥ ; ៧ ; ៩ ; ១១ ; ១៣ ; ១៥ ; ១៧ ; ១៩ ;

ខ)– ពី ២០ ចុះមក ១, បន្ថយម្ដង ២.

១៨; ១៦ ; ១៤ ; ១២ ; ១០ ; ៨ ; ៦ ; ៤ ; ២;

**មេរៀន** .– បង្រៀនឲ្យរាប់ពី ១ ដល់ ៣០.

**បង្កើនម្ដង ២** .– គ្រូកាន់ចង្កឹះចំនួន ២ នៅដៃម្ខាង ហើយ ២ ទៀត នៅដៃម្ខាងទៀត ។ គ្រូសួរសិស្សថា : នៅដៃស្ដាំលោកគ្រូមានចង្កឹះប៉ុន្មាន ? – សិស្សឆ្លើយថា : ចង្កឹះ ២ ។ គ្រូសួរទៅទៀតថា : នៅដៃឆ្វេងលោកគ្រូមានចង្កឹះប៉ុន្មាន ? – សិស្សឆ្លើយថា : ចង្កឹះ ២ ។

គ្រូនិយាយហើយសួរថា : ខ្ញុំមានចង្កឹះ ២ ខ្ញុំថែមចង្កឹះ ២ ទៀត ទៅលើចំនួនចង្កឹះដែលខ្ញុំមាន តើខ្ញុំមានចង្កឹះទាំងអស់ប៉ុន្មាន? សិស្សឆ្លើយថា : លោកគ្រូមានចង្កឹះទាំងអស់ ៤ រួចហើយឲ្យសិស្សរាប់ចង្កឹះដែលមានក្នុងដៃគ្រូ ។ គ្រូសរសេរលេខ ២, ៤ នៅលើក្ដារខៀនឲ្យសិស្សមើលហើយឲ្យសរសេរតាមទៅលើក្ដារឆ្នួនរបស់វា ។

គ្រូកាន់យកចង្កឹះ ២ ទៀត ដើម្បីនឹងបន្ថែមទៅលើចំនួនចង្កឹះ ៤ ដែលក្មេងបានរៀនរួចអម្បាញ់មិញ ។ សិស្សឆ្លើយហើយរាប់ឃើញចង្កឹះ ៦ ។ គ្រូសរសេរហើយឲ្យសិស្សរាប់នឹងសរសេរតាម ។

សូមឲ្យគ្រូធ្វើយ៉ាងដូច្នេះរហូតដល់ទៅចំនួន ៣០ ដូចមានតទៅនេះ៖

២; ៤; ៦; ៨; ១០; ១២; ១៤; ១៦; ១៨: ២០; ២២; ២៤; ២៦; ២៨; ៣០ ។

(ឲ្យសិស្សមើល, សរសេរហើយរាប់បង្កើនតាមចំនួនខាងលើនេះ) ។

បង្កើនម្ដង ៣ : ធ្វើដូចខាងលើ

---

បង្កើនម្ដង ៤ : ធ្វើដូចខាងលើ

---

បង្កើនម្ដង ៥ : ធ្វើដូចខាងលើ

---

បង្រៀនឲ្យធ្វើលេខបូកនឹងលេខសងមានលេខតែមួយខ្ទង់

**លេខបូកមានលេខតែមួយខ្ទង់** - ខ្ញុំមានបីកាក់ក្នុងហោប៉ៅអាវខ្ញុំ នៅក្នុងហោប៉ៅមួយទៀតខ្ញុំមានបួនកាក់ ខ្ញុំលូកយកប្រាក់ទាំងអស់នេះមករាប់ខ្ញុំរាប់ទៅឃើញប្រាំពីរកាក់ ។ ធ្វើយ៉ាងនេះគឺខ្ញុំធ្វើលេខបូក ខ្ញុំថា បីកាក់នឹងបួនកាក់ត្រូវជាប្រាំពីរកាក់ ។ ខ្ញុំសរសេរលេខយ៉ាងដូច្នេះ ៣ + ៤ = ៧ ឬ ៤ + ៣ = ៧

ខ្ញុំមើលថាយ៉ាងដូច្នេះ បីផ្សំនឹងបួនត្រូវជាប្រាំពីរ ឬ បួនផ្សំនឹងបីត្រូវជាប្រាំពីរ ។ ឯប្រាំពីរ សន្មតហៅថាចំនួនរួម ។ សញ្ញាសំរាប់លេខបូក គឺគំនូស កាកបាទ ( + ) គេហៅថាផ្សំ ឬ ថែម ។

**លេខសងមានលេខតែមួយខ្ទង់** – មានព្រាបប្រាំបី ហើរទៅបី នៅសល់ប៉ុន្មាន ? ឥឡូវខ្ញុំរាប់ព្រាបនៅសល់ ខ្ញុំរាប់ឃើញព្រាបប្រាំ ធ្វើយ៉ាងនេះគឺធ្វើលេខសង ខ្ញុំថាយកបីទៅដកពីប្រាំបីនៅសល់ប្រាំ ឬព្រាបប្រាំបីដកបីចេញនៅសល់ព្រាបប្រាំ ។ ខ្ញុំសរសេរលេខយ៉ាងដូច្នេះ៖ ៨–៣=៥ ខ្ញុំមើលថាយ៉ាងដូច្នេះប្រាំបីដកបីចេញនៅសល់ប្រាំ ឯប្រាំហៅថាសេស ។ សញ្ញាសំរាប់លេខសង គឺឆូតមួយ ( – ) ហៅថាដក ។

**វិធីហាត់គិតមាត់ទទេនិងហាត់សរសេរ** - (សូមមើលក្នុងសៀវភៅក្បួននព្វទ្ធិខ្មែរថ្នាក់អាចិកដ្ឋាន ទំព័រ ៧ )

## រង្វាស់រង្វាល់

រង្វាស់តូចជាងរង្វាស់ខ្នាតម៉ែត្រ.

ដេស៊ីម៉ែត្រ, សង់ទីម៉ែត្រ, ដេស៊ីម៉ែត្រក្លោះ

### មេរៀនទី ១ .– ដេស៊ីម៉ែត្រ -

ក ) វិធីពិនិត្យរង្វាស់

១–គ្រូលើករង្វាស់ដេស៊ីម៉ែត្រ ហើយប្រាប់សិស្សថានេះរង្វាស់ឈ្មោះថា “ដេស៊ីម៉ែត្រ” ។

២)-- គ្រូសរសេរឈ្មោះរង្វាស់នោះនៅលើក្ដារខៀនគ្រប់តួអក្សរ “ដេស៊ីម៉ែត្រ”. និងកាត់ “ដ.ម.” ។

៣)- គ្រូឲ្យសរសេរហើយឲ្យមើល ។

៤)- គ្រូឲ្យសិស្សពិនិត្យរង្វាស់នោះ (ប្រវែង, ពណ៌, ពង, ទម្ងន់, ឈើស្រាល, លេខ, កំរិត . . . ) ។

៥)- គ្រូឲ្យសិស្សគូសបន្ទាត់ប្រវែង ១ ដេស៊ីម៉ែត្រនៅលើក្ដារខៀន ឲ្យពេរីកបង្ហាញ ហើយវាស់បញ្ជាក់តំនូសទាំងនោះ នឹងរង្វាស់ដេស៊ីម៉ែត្រ ។

៦)- វិធីហាត់ស្មានប្រវែងគ្មានប្រើរង្វាស់ដេស៊ីម៉ែត្រ និង វិធីបង្រៀនសិស្សឲ្យចេះវាស់ឲ្យត្រឹមត្រូវ :-

១)- គ្រូលើកបន្ទាត់មួយឲ្យសិស្សមើល ហើយបង្គាប់ឲ្យសិស្សស្មានប្រវែងបណ្ដោយបន្ទាត់នោះ ដោយកត់ត្រាពាក្យឆ្លើយនៅលើក្ដារខៀនរៀងខ្លួន ។

២)- គ្រូបង្គាប់ឲ្យលើកក្ដារខៀន ហើយត្រួតត្រាមើល ។ បើមានសិស្សណាមួយឆ្លើយខុសឆ្ងាយពេក ពីប្រវែងបន្ទាត់មែនទែន នោះគ្រូហៅសិស្សនោះមកកាន់ដេស៊ីម៉ែត្រ វាស់បន្ទាត់ ដែលត្រូវរកប្រវែងបណ្ដោយ ។

(ក្នុងខណៈពេលដែលសិស្សវាស់បន្ទាត់នឹងរង្វាស់ដេស៊ីម៉ែត្រនោះ គ្រូគោងមើលត្រួតត្រា ហើយបង្ហាញសិស្សឲ្យចេះកាន់ហើយនិងឲ្យចេះវាស់) ។

៣)- គ្រូបង្ហាញវត្ថុផ្សេងៗដទៃទៀត ឲ្យសិស្សស្មានប្រវែងដូចជាស្មានប្រវែងបន្ទាត់ដែរ ៗ រួចហើយឲ្យសិស្សវាស់បញ្ជាក់ប្រវែងវត្ថុទាំងនោះ ៗ

គ)- វិធីហាត់សរសេរ

១- គ្រូពោលចំណោទមួយឲ្យសិស្សប្រុងស្តាប់ហើយឲ្យសិស្សគិតដោយមតិសំខ្យា រួចកត់ត្រាទុកនៅលើក្តារខៀនរៀងខ្លួនដូចជាឧទាហរណ៍ខាងក្រោមនេះ ៖

បងខ្ញុំគាត់មានខ្សែអម្បោះ ៩ ដ.ម ៗ គាត់កាត់យកទៅប៉ះខោការអស់ ៦ ដ.ម ៗ សួរថា តើគាត់នៅសល់អម្បោះប៉ុន្មានដេស៊ីម៉ែត្រទៀត? ៗ (ចំណោទនេះគ្រូពោលមាត់ទទេកត់ត្រាលើក្តារខៀនតែលេខប្រាប់ចំនួនបានហើយ) ៗ

មេរៀនទី ២.- សង់ទីម៉ែត្រ (បង្រៀនដូចគ្នា)

មេរៀនទី ៣.- ដេស៊ីម៉ែត្រក្រោះ (បង្រៀនដូចគ្នា) ៗ

# មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

## វិទ្យាសាស្ត្រ

អាទិត្យទី ១.–　　　　មេរៀនទី ១ –

### អំពីការដកដង្ហើម

ប្រដាប់បង្រៀន.– ផ្ទាំងគំនូរគ្រឿងប្រដាប់ដកដង្ហើម មានរូបសួតផា ដើម ។ល។

ការពិនិត្យមើល.– ហៅសិស្សម្នាក់ឲ្យដោះអាវចេញ នៅតែខ្លួនទទេ ទៅឈរនៅមុខគុសិស្ស រួចបង្គាប់ឲ្យវាដកដង្ហើមចូលយ៉ាងខ្លាំង នាំសិស្សឯទៀតពិនិត្យមើល ឃើញដើមទ្រូងឡើងធំប៉ោង ដោយអាកាសចូលពេញសួតនៃសិស្សនោះ ។ បង្គាប់ឲ្យវាដកដង្ហើមចេញ យើងឃើញថាទ្រូងវាត្រឡប់ជាតូចដូចធម្មតាវិញ ។ ដូច្នេះយើងគ្រាន់តែបរិភោគអាហារ មិនអាចឲ្យជីវិតយើងរស់នៅបានឡើយ ។

គ្រឿងប្រដាប់សំរាប់ដកដង្ហើម .— ខ្យល់ដែលយើងដកដង្ហើមចូលទៅក្នុងខ្លួនតាមច្រមុះឬតាមមាត់ រួចចុះទៅក្នុងសួតតាមបំពង់មួយហៅថាបំពង់ខ្យល់ធំ ៗ សួតជាប្រដាប់ដកដង្ហើម នៅសឹងតែពេញទ្រូង មានឆ្អឹងជំនីរបិទបាំងការពារជុំវិញ ។ ខ្យល់ចូលតាមបំពង់ខ្យល់ធំ (Trachée-artère) ដល់ទង្រួមដើមសួតខាងលើ បំពង់ខ្យល់ធំនេះបែកជាបំពង់ខ្យល់តូច ៗ ពីរ (Bronches) បំពង់មួយចូលទៅក្នុងសួតមួយ ហើយបែកផ្លូវគ ៗ ក្លាជាបំពង់តូច ៗ ច្រើនទៅទៀត (branchioles) នៅខាងចុងបំពង់តូច ៗ នេះមានក្រពះខ្យល់តូច ៗ ច្រើនទៅទៀត (Alvéole pulmonaire)

វិធីដកដង្ហើម .— កាលណាយើងដកដង្ហើម ខ្យល់ចូលទៅក្នុងសួត យើងហៅថា ដកដង្ហើមចូល វេលានោះសួតក៏ប៉ោងហើយទ្រូងក៏ហើបឡើង ។ មួយរំពេចខ្យល់នោះក៏ចេញពីសួតមកវិញតាមផ្លូវដដែល ហើយទ្រូងក្ដាបទៅវិញ វេលាដែលខ្យល់ចេញពីសួតមកវិញនេះ យើងហៅថាដកដង្ហើមចេញ ។

ការដកដង្ហើមចូលនិងចេញកំណត់ប្រហែលបួនសិកុង (4 secondes) គឺក្នុងមួយមីនុត យើងដកដង្ហើមបាន១៥ឬ១៦ដង ។ យើងដកដង្ហើមម្តងខ្យល់ចូលទៅក្នុងសួតយើងបានចំនួនប្រហែលកន្លះលីត្រ ។

ប្រយោជន៍នៃការដកដង្ហើម .— ខ្យល់ដែលយើងដកដង្ហើមមិនមានតែប្រយោជន៍ឲ្យយើងមានជីវិតរស់នៅនោះទេ គឺខ្យល់នេះបណ្ដាលឲ្យយើងនិយាយបានតាមចិត្ត ខ្យល់នេះស្ទុះចេញពីកន្សួតយ៉ាងខ្លាំង កើតបានជាពាក្យសំដីដោយចំណែកខាងលើនៃបំពង់ខ្យល់ធំ(Larynx) ។

មេរៀនសង្ខេប.— ខ្យល់ដែលយើងដកដង្ហើមនោះ ចូលទៅកន្សួតតាមច្រមុះ មាត់ ចុះទៅតាមបំពង់ខ្យល់ធំ បំពង់ខ្យល់តូចនិងបំពង់តូចៗទៅទៀតជាច្រើន ។ កាលណាយើងដកដង្ហើមចូល សួតយើងប៉ោងឡើងហើយទ្រូងក៏ប៉ោងឡើងដែរ ។ កាលណាយើងដកដង្ហើមចេញ សួតក៏ផតទ្រូងក៏ក្ដោបតូចដូចដើមវិញ ។ យើងដកដង្ហើមចូល-ចេញដូច្នេះក្នុងមួយមិនុតបាន១៥ឬ១៦ដង ។ ដកដង្ហើមមួយដង·ខ្យល់ចូលទៅកន្សួតយើងបានចំនួនប្រហែលកន្លះលីត្រ ។

ខ្យល់ចេញ-ចូលកន្សួតយើងនេះ មិនគ្រាន់តែឲ្យមានជីវិតរស់នៅនោះទេ គឺបណ្ដាលឲ្យយើងនិយាយស្ដីបានតាមត្រូវការ ដោយអំណាចចំណែកខាងលើនៃបំពង់ខ្យល់ធំ ។

ពាក្យសួរក្នុងមេរៀន .— កាលណាយើងដកដង្ហើម តើខ្យល់ចូលទៅកន្សួតយើងតាមអ្វី ? សួតនិងទ្រូងយើងដូចម្ដេច កាលណាយើងដក

ដង្ហើមចូល ? ដកដង្ហើមចេញ ? តើក្នុងមួយម៉ឺនុតយើងដកដង្ហើមបាន ប៉ុន្មានដង ? តើដកដង្ហើមម្តងខ្យល់ចូលទៅខ្លួនយើងបានប៉ុន្មានលីត្រ ? ខ្យល់ដែលយើងដកដង្ហើម តើមានប្រយោជន៍អ្វីខ្លះ ?

អាទិត្យទី ២– ១ – អំពីការឈាមរត់ក្នុងខ្លួន ។

២– អំពីការបញ្ចេញវត្ថុមិនស្អាតទៅក្រៅខ្លួន ។

(សូមបង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍បរិច្ឆណដ្ឋានទំព័រទី ១៦ ដល់ទី ២០ ).

អាទិត្យទី ៣ – ១- បិដ្ឋាដ្ឋិកសត្វនឹងនិបដ្ឋាដ្ឋិកសត្វ ។

២– បិដ្ឋាដ្ឋិកសត្វ-ថនិកសត្វ ។

(មើលសៀវភៅវត្ថុស្វាធ្យាយន៍បរិច្ឆណដ្ឋានតាំងពីទំព័រទី ២៩ ដល់ទំព័រទី ៣២ ។ )

អាទិត្យទី៤– សូមសាបង្រៀនមេរៀនក្នុងវគ្គនេះឡើងវិញ ។

## វិធីបង្ការរោគ

អាទិត្យទី ១ – មេរៀនជាគំរូ

# អំពីការថែរក្សាត្រចៀក

យើងត្រូវដឹងថាត្រចៀកយើងជាវិញ្ញាណមួយ យ៉ាងសំខាន់ណាស់ គឺត្រចៀកនេះហើយអាចឲ្យយើងស្តាប់សូរសំឡេងផ្សេង ៗ ដែលមាននៅជុំវិញខ្លួនយើង ។ ប្រយោជន៍ឲ្យត្រចៀកស្តាប់សូរសព្ទទាំងឡាយនេះបាន ដោយងាយ យើងត្រូវថែរក្សាត្រចៀកយើងដូចមានខាងក្រោមនេះ ៖

១ ១- ត្រូវឲ្យរន្ធត្រចៀកស្អាតជាដរាប គឺកុំឲ្យមានវត្ថុអ្វីមកខាំងរន្ធត្រចៀកឲ្យសោះ បើមានវត្ថុអ្វីស្ទះរន្ធត្រចៀកនោះហើយ សូរទាំងឡាយមិនអាចនឹងចូលទៅក្នុងត្រចៀកបានឡើយ ។

១ ២- នៅខាងក្នុងរន្ធត្រចៀកមានស្បែកមួយយ៉ាងស្តើងជាបំផុត សំរាប់ទទួលប៉ះសំឡេងទាំងឡាយបានដោយងាយណាស់ ហៅថាក្រដាសត្រចៀក ហេតុនេះយើងត្រូវថែរក្សាក្រដាសត្រចៀកនោះឲ្យស្អាតជាដរាប ប្រយ័ត្នកុំឲ្យធ្លុះធ្លាយឲ្យសោះ ។

ក)– ត្រូវយកចំណិតឫស្សីតូចមួយ មករុំនឹងសំឡីត្បារត្រចៀកបានហើយ ។

ខ)– ត្រូវចៀសវាងកុំយករបស់ស្រួចដូចជាម្ជុលបាកំង ស្នៀតសក់ ឈើស្រួចជាដើមមកត្បារត្រចៀក ។ល។ . .

គ)– កុំឲ្យជាងកាត់សក់យកបង្កៀលដែលវាកៀល ឲ្យមនុស្សច្រើននាក់មកត្បារត្រចៀកឲ្យអ្នក ខ្លាចឆ្លងជម្ងឺផ្សេងៗ ពីមនុស្សមុនៗ មកដល់អ្នកទៀត ។ល។ .

ឃ)– បើសិនណាជាមានសត្វអ្វី ចូលក្នុងត្រចៀកអ្នក អ្នកមិនត្រូវឆ្កឹះកកាយ ឲ្យរហែកស្បែកត្រចៀកអ្នកទេ ទុកឲ្យសត្វនោះចេញមកវិញខ្លួនវា ។ បើជាវាក្រចេញមកវិញ អ្នកយកសំឡីចុករន្ធត្រចៀកអ្នកឲ្យជិត សត្វនោះនឹងស្លាប់ដោយឥតខ្យល់អាកាសជាពុំខានឡើយ ។

ង)– កុំយកម្រាមដៃកខ្វក់ ទៅលូកក្នុងរន្ធត្រចៀកឲ្យសោះ វាបណ្ដាលឲ្យកើតជម្ងឺធ្ងន់បាន ។ បើអ្នកឈឺត្រចៀក ចូរទៅមន្ទីរព្យាបាលរោគឲ្យពិនិត្យមើលរោគ ហើយដាក់ថ្នាំឲ្យ ។

ច)- លោកគ្រូត្រូវធ្វើកិច្ចនេះឲ្យពិស្ដារបង្ហាញសិស្ស គឺសំអាតត្រចៀកខ្លួនឯងឲ្យសិស្សមើល ឬ សំអាតត្រចៀកសិស្សណាមួយនៅចំពោះមុខសិស្សទាំងអស់ ។ បង្ហាញសិស្សរបស់ណាដែលត្រូវយកមកប្រើ របស់ណាខ្លះដែលមិនត្រូវយកមកត្បារសំអាតត្រចៀក ។

មេរៀនសង្ខេប .– សោតវិញ្ញាណ ជាគ្រឿងប្រដាប់សំរាប់ឮសូរ

សម្ងន់ ៗ យើងត្រូវសំអាតត្រចៀកយើង កុំឲ្យមានអ្វីស្ទះរន្ធ ត្រចៀកនោះឡើយ ៗ ត្រូវត្បារសំអាតត្រចៀកយើងតែនឹងវត្ថុស្អាត គឺយកបំណិតបុស្សីមួយតូច មករុំសំឡីត្បារត្រចៀក - យ៉ាងតិច ៗ បាន ហើយ ៗ មិនត្រូវយករបស់ស្រួច រឹង មកត្បារត្រចៀកទេ ពីព្រោះវត្ថុ នោះនាំឲ្យមានរបួសដល់សោតបសាទ (គឺទ្វារសំពត្ថ) ៗ កុំឲ្យជាង កាត់សក់ យកបង្កៀលដែលវាកៀលឲ្យមនុស្សច្រើននាក់ មកកៀល ត្រចៀកឲ្យយើងទៀត ខ្លាចឆ្លងជម្ងឺផ្សេង ៗ ពីមនុស្សទាំងនោះ ជម្ងឺ ដែលវាចម្លងមកនេះបណ្តាលឲ្យយើងធ្ងន់ ឬឲ្យយើងថ្លង់ផងក៏បាន ៗ

**ពាក្យសួរក្នុងមេរៀន** .— សោតវិញ្ញាណ ជាគ្រឿងប្រដាប់ដូចម្តេច ? ត្រូវសំអាតត្រចៀកយើងឬទេ ? ត្រូវសំអាតដូចម្តេចខ្លះ ? យើង ត្រូវចៀសវាងវត្ថុអ្វីខ្លះ ដែលមិនត្រូវយកមកត្បារត្រចៀកយើង ? ពីព្រោះអ្វី ? បើចង់ត្បារត្រចៀក តើត្រូវត្បារនឹងអ្វី ? ។ល។

## អាទិត្យទី ២ – អំពីជម្ងឺអុត និង ជម្ងឺឃ្លង់

(សូមមើលមេរៀននេះក្នុងសៀវភៅសិក្សាវិទ្យាសាស្ត្រ ឧត្តមដ្ឋាន (ភាសាបារាំង) ត្រង់ទំព័រទី ៤០ និង ៤១).

## អាទិត្យទី ៣ អំពីព្រូន.

(សូមមើលសៀវភៅដដែល ទំព័រទី ៤២ – ៤៣)

អាទិត្យទី ៤– សាបង្រៀនពីក្នុងខែនេះឡើងវិញ ។

# មធ្យមដ្ឋាន

## វិត្តស្វាធ្យាយន៍

អាទិត្យទី ១.– ថនិកសត្វ. ប្រដាប់សម្រាប់បង្រៀន.– ផ្ទាំងគំនូររូបថនិកសត្វមកបង្ហាញសិស្សមានរូបឆ្កែ, ឆ្មា, សេះ, ដំរី, ជ្រូក, គោជាដើម ។

លក្ខណៈនៃថនិកសត្វ.– ចូរពិនិត្យមើលសត្វគោ-មានអ្វីព័ទ្ធជុំវិញខ្លួនគោ? ( រោម ) វាពងឬវាសំរាលកូនមកតែម្ដង? វាចិញ្ចឹមកូនវានឹងអ្វី? សត្វអ្វីខ្លះដែលមានរោមព័ទ្ធជុំវិញខ្លួន ហើយចិញ្ចឹមកូននឹងទឹកដោះ ពួកសត្វនេះជាពួកថនិកសត្វ ( ថនៈឬថនា=ដោះ ) ថនិកសត្វជាសត្វឈាមក្ដៅគឺចំហាយឈាមមិនផ្លាស់ប្ដូរតាមរដូវឡើយ ។ គេចែកថនិកសត្វជាច្រើនពួកៈ មំសាហារសត្វ, សត្វទំពាអៀង, សត្វមិនទំពាអៀង ។

### មំសាហារសត្វ

ប្រដាប់សម្រាប់បង្រៀន.– ឆ្មានឹងផ្ទាំងគំនូរខ្លាធំ, រខិននឹងឆ្មាព្រៃ ។

សត្វជាគំរូ.– ឆ្មា ។ សូមគ្រូបង្រៀនតាមសៀវភៅវត្តស្វាធ្យាយន៍សំរាប់មធ្យមដ្ឋានទី ១ ទំព័រទី ៣៤-៣៥- ។

អាទិត្យទី ២ .– សត្វទំពាអៀង ។

ប្រដាប់សម្រាប់បង្រៀន– ថ្គាមគោ, ស្នែង–គំនូរក្រពះគោនឹងក្របី, ពពែ, ដាម, រមាំង, ឈ្លូស ។

សត្វជាគំរូ.- គោ ។ សូមមើលសៀវភៅដដែលទំព័រទី ៣៦-៣៧ ។

អាទិត្យទី ៣ សត្វមិនទំពាអៀង-

ប្រដាប់សម្រាប់បង្រៀន.- សេះ,ជ្រូកឬដំរី ។

សត្វជាគំរូ.- សេះ-ដំរី ។ សូមមើលសៀវភៅវត្ថុស្វាធ្យាយន៍ សំរាប់ឧត្តមជាន់ទំព័រទី ១០៤-១០៥- ។

អាទិត្យទី ៤- បក្សី ។

ប្រដាប់សម្រាប់បង្រៀន- មាន់ ។

លក្ខណៈបក្សី– មាន់ មានលក្ខណៈផ្សេងពីថនិកសត្វដូចម្ដេចខ្លះ? មានអ្វីព័ទ្ធខ្លួន?មានជើងប៉ុន្មាន? មានធ្មេញឬទេ? មាន់បង្កើតកូនតែម្ដង ឬពងសិន?

សូមមើលមេរៀនចំពូកនេះក្នុងសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់អាទិក- ជាន់ទំព័រទី ២៥-២៦ ។

# អាទិកដ្ឋាន

## វិត្តស្វាយព្យាយន៍

### អាទិត្យទី ១.– អំពីសត្វព្រៃ

អំពីខ្លា – គ្រូត្រូវរកផ្ទាំងគំនូរដែលមានរូបសត្វព្រៃបង្ហាញសិស្ស ។

ខ្លួនខ្លា – នាំសិស្សពិនិត្យមើលរូបរាងសត្វខ្លា ។ ឲ្យសិស្សសង្កេតមើលខ្លួនខ្លា ។ រាងដូចម្ដេច ? ។ ឲ្យសង្កេតមើលក្បាល, មាត់ ។

ក្រចកខ្លា: ខ្លាមានជើងប៉ុន្មាន ? សត្វដែលមានជើងបួនហៅសត្វអ្វី ? នៅចុងជើងមានអ្វី ? ក្រចកខ្លាមានសណ្ឋានបែបណា ? (កោងខ្លុបចុះក្រោមស្រួចលបចូលលូតចេញបានតាមចិត្ត) ឯក្រចកនេះសម្រាប់អ្វី?(ចាប់ក្រញាំសត្វជាអាហារ) ធ្មេញខ្លាស្រួចហើយរឹង ៗ ចង្កូមវារឹងហើយមុតណាស់ ។ ខ្លួនខ្លារាងទន់ភ្លន់ហើយរហ័សណាស់ ។

អាហារខ្លា:– ខ្លាស៊ីអ្វី ? វាចាប់សត្វអ្វីខ្លះយកមកបរិភោគ ? សត្វដែលបរិភោគសាច់ឆៅគេហៅសត្វអ្វី ? (មំសាហារសត្វ) ខ្លានៅជិតមនុស្សឬទេ? វាច្រើននៅឯណា? ខ្លាកាចឬស្លូត? គេបាញ់យកស្បែកវាធ្វើអ្វី? ក្រចកវាគេធ្វើអ្វី?

## អាទិត្យទី ២- អំពីពស់

ប្រដាប់សំរាប់បង្រៀន— គ្រូត្រូវរកពស់ត្រាំស្រាដាក់កែវយកមកបង្ហាញសិស្ស បើគ្មានដូច្នេះទេត្រូវរកផ្ទាំងគំនូរដែលមានរូបទវង្គសត្វ ។ នាំសិស្សសង្កេតមើលរូបរាងពស់យ៉ាងដូចម្តេច?(វែងដូចអន្ទង់)គេឃើញមានអ្វីនៅពាសពេញខ្លួនវា? (មានស្រកា)

មេរៀនសង្ខេប— ទវង្គសត្វគឺជាសត្វមានឈាមត្រជាក់ ខ្លួនសត្វនេះគ្មានរោមទីងស្លាបទេមានតែស្រកាពាសពេញជុំវិញខ្លួនហើយលូនលើដី ។ ពស់គ្មានជើងទេ ។ ពស់ខ្លះដូចជាពស់សម្លាប់កង្កែបដែលជាពស់គ្មានពិសទេ ។ ខ្លះមានពិសចិកស្លាប់ដូចជាពស់វែកជាដើម ។ ពស់ថ្លាន់គ្មានពិសទេប៉ុន្តែវាអាចរិតមនុស្សស្លាប់បានដោយវាធំហើយវាខ្លាំងផង ។ ពស់សកតាមរដូវ ។

មើលមេរៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់អាទិកដ្ឋានទំព័រទី២៧ ។

## អាទិត្យទី៣ - ការបរបាញ់-

ប្រដាប់សម្រាប់បង្រៀន — នេសាទុបករណ៍ខ្លះដូចជា-ស្នា - ធ្នូ- ព្រួញមូល-អន្គប់- ដង់-បន្ទឹង ។ល។

ពាក្យសួរ - គេចាប់សត្វឬសម្លាប់សត្វ ដោយវិធីបែបណាខ្លះ?(ទាក់-បាញ់

ឬដាក់ថ្នាំបំពុល) សត្វអ្វីខ្លះដែលគេបំផ្លាញដោយវាជាសត្វចង្រៃ? សត្វអ្វីខ្លះដែលគេបាញ់ឬដាក់អន្ទប់យកសាច់ជាអាហារ? គេបាញ់ខ្លាយកអ្វីវា? ដំរីយកអ្វី? សត្វណាខ្លះដែលគេបាញ់យកស្បែក? យកស្នែង? យកភ្លុក? យកមកធ្វើថ្នាំ?

## អាទិត្យទី៤.— អំពីនេសាទ

**នេសាទឧបករណ៍** - អួន- មង- សំណាញ់. អញ្ចាង- ឆ្នុក- គន - អង្រុត លប ទ្រូ—សៃយឺន ។ល។

នៅនគរខ្មែរកន្លែងចាប់ត្រីធំបំផុតនៅតំបន់ណា? គេចាប់ពីក្នុងបឹងទន្លេសាបមកធ្វើអ្វីខ្លះ? គេធ្វើទឹកត្រីបែបណា? គេឆ្អើរត្រីដូចម្ដេច? គេធ្វើត្រីងៀតដូចម្ដេច? ប្រហុកដូចម្ដេច? ទឹកត្រីដូចម្ដេច? គេយកអ្វីក្នុងចំណែកខ្លួនត្រីទៅធ្វើការ? ការនេសាទត្រីនេះចំរើនដល់ភោគសម្បត្តិនគរយើងឬទេ?

**មេរៀនសង្ខេប**- នគរកម្ពុជាការនេសាទត្រីធំបំផុតមាននៅបឹងទន្លេសាប ។

ឯត្រីដែលចាប់បានមកគេយកមកធ្វើត្រីងៀត, ត្រីឆ្អើរ, ប្រហុក, ទឹកត្រី, ផ្អក, ខ្លាញ់ទីងការផងៗ

គេនាំត្រីងៀតទៅលក់ច្រើននៅស្រុក (សិង្ហបុរី) សង្គបុរ ហើយនឹងប្រទេសចិន ។

# មជ្ឈិមដ្ឋានទី ១

## វិធីបង្ការរោគ

### អាទិត្យទី ១.— ការថែរក្សាទីលំនៅ

សូមមើលទស្សនាវដ្ដីខែកញ្ញា ត្រង់ទំព័រសម្រាប់អាទិកដ្ឋាន ហើយបន្ថែមសេចក្ដីខ្លះទៀតផង ។

### អាទិត្យទី ២.— សត្វរស់នៅនឹងខ្លួនមនុស្ស

សត្វរស់នៅនឹងខ្លួនមនុស្សមានពីរពួកៈ មួយពួកដែលយើងអាចមើលឃើញដូចជាចៃ, សង្កើច, មូស, ព្រូននឹងមេក្រមុំរមាស់ ។ មួយពួកទៀតយើងមើលដោយភ្នែកពុំឃើញទេ គឺជាៈ អតិសុខុមប្រាណ ។ ដែលអាចបង្កជម្ងឺៈ គ្រុនធ្ងន់, គ្រុនសាចុះឡើង, ឃ្លង់ ។

មានចៃពីរយ៉ាងៈ ចៃក្បាល ១ យ៉ាង ចៃខ្លួនឬចៃសំពត់អាវ ១ យ៉ាង ។ ចៃទាំងអស់សុទ្ធតែស្មោកគ្រោកដូចគ្នា គួរឲ្យខ្ពើមណាស់ ។ ចៃក្បាលច្រើននៅក្នុងផងសក់ ច្រើននៅក្នុងសក់ក្បាលមនុស្សណាដែលវែង ៗ ។ ចៃខ្លួនឬចៃសំពត់អាវច្រើន មាននៅដោយសំលៀកបំពាក់ហើយចូលចិត្តនៅតែសំលៀកបំពាក់ណាដែលប៉ះពាល់ផ្ទាល់នឹងស្បែក ។

ត្រូវប្រយ័ត្នកុំឲ្យសង្កើបនៅក្នុងដំណេក ។ ត្រូវដេញបំបាត់មូសកុំឲ្យវាខាំ ពីព្រោះមូសខាំបណ្ដាលឲ្យទៅជាគ្រុនចាញ់ ។ គ្រូនច្រើននៅក្នុងពោះវៀន ។ សត្វនេះកើតមកអំពីចំណីអាហារមិនឆ្អិន ។ រមាស់បណ្ដាលកើតមកពីការស្មោកគ្រោក ។

## អាទិត្យទី ៣ .— ជម្ងឺសើស្បែក

សេចក្ដីរំឭក .— ជម្ងឺសើស្បែកទាំងប៉ុន្មាន (កម, បូសទ្រនិច, បូសបណ្ដើរកូន, ដំបៅឆា, ដំបៅពក) សុទ្ធសឹងបណ្ដាលពីមេរោគទាំងអស់ដែលជាហេតុនាំឲ្យឆ្លង ដូច្នេះកុមារដែលកើតរោគនេះគោងតែសំអាតខ្លួនឲ្យណាស់ ត្រូវកាត់ក្រចកដៃឲ្យអស់ចេញត្រូវរកថ្នាំលាបទើបជា ។ ឯកុមារដែលគ្មានកើតរោគនេះត្រូវកុំឲ្យប៉ះពាល់នឹងកុមារឈឺ ឬក៏យករបស់អ្វីនៃកុមារនេះមកប្រើប្រាស់ឲ្យសោះ ។

## អាទិត្យទី ៤ .— កិច្ចដែលត្រូវធ្វើក្នុងពេលមានរោគរាតត្បាត (អាសន្នរោគ, ពិស បារាំងហៅថាប៉េស្ដ ។

បំពោះជម្ងឺអាសន្នរោគ- ១ -ត្រូវដាំទឹក - បំអិនបន្លែឲ្យឆ្អិនហើយគ្របចំណីអាហារកុំឲ្យរុយទំ ។

២- ត្រូវស្អាតឲ្យណាស់ ។

៣ - ត្រូវបាក់ថ្នាំការពារខ្លួន ។

ចំពោះជម្ងឺប៉េស្ត- ដូចគ្នានឹងជម្ងឺអាសន្នរោគដែរ តែត្រូវជៀសវាងសង្កើចនឹងត្រូវចាប់កណ្តុរសម្លាប់ដុតចោល ។

# អាទិកដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១ – ជម្ងឺភ្នែក .– ជម្ងឺភ្នែកមានពីរយ៉ាង៖ ជម្ងឺភ្នែកមានខ្ទុះហូរចេញនិងជម្ងឺភ្នែកឡើងបាយ ។ ជម្ងឺនេះឆ្លងឬទេ? ដូច្នេះត្រូវធ្វើម្តេច? (កុំឲ្យមមង់ឬរុយរោម) កុំយកដៃឬកំណាត់កខ្វក់ជូតភ្នែក ។

ជម្ងឺភ្នែកមានខ្ទុះហូរចេញមានលក្ខណៈយ៉ាងណា? (ត្របកភ្នែកហើម, កែវភ្នែកក្រហម, មានខ្ទុះហូរចេញជានិច្ច, ភ្នែកឡើងងាសមើលអ្វីមិនច្បាស់) ជម្ងឺភ្នែកឡើងបាយមានលក្ខណៈបែបណា? (បែបគ្នានឹងជម្ងឺភ្នែកមានខ្ទុះដែរ តែនៅខាងក្នុងត្របកភ្នែកមានឡើងបាយដុំតូចៗ ។

ដុំនេះទុកយូរទៅនឹងកើតជាដំបៅដោយរោមភ្នែកជូត ។ ត្រូវដាក់ថ្នាំកុំបណ្តោយ ពុំនោះទៅភ្នែកនឹងខូច) ។

អាទិត្យទី២ ការថែរក្សាភ្នែក .– កុំពាល់ភ្នែកនឹងម្រាមដៃ -ត្រូវជៀសវាងកុំឲ្យប៉ះទង្គិចនឹងអ្វី, កុំឲ្យត្រូវខ្យល់, ធូលីឬផ្សែង ៗ ត្រូវខ្ចាបពន្លឺចាំងខ្លាំងដោយកុំមើលថ្ងៃ ៗ ត្រូវដាក់សៀវភៅមើលចម្ងាយ៣០ស.មពីភ្នែក ៗ បើភ្នែកឡើងក្រហមត្រូវលាងនឹងទឹកក្តៅ បើពុំជាត្រូវទៅរកពេទ្យមើលកុំបណ្តោយ ៗ

អាទិត្យទី៣.–ការថែរក្សាត្រចៀក.– ត្រូវជូតស្អឹកត្រចៀកឲ្យស្អាតជានិច្ច បើទឹកចូលត្រចៀកត្រូវប្រញាប់ត្បារចេញឲ្យអស់តែទុកនឹងបណ្តាលឲ្យកើតអំបៅអំបែកខួបត្រចៀក – កុំត្បារត្រចៀកនឹងរបស់រឹងឬស្រួចខ្ចាបជ្រុលដៃនាំឲ្យធ្លាយក្រដាសត្រចៀកឬកោសដាច់សាច់ខាងក្នុង ត្រូវប្រើសំឡីក្នុងការត្បារត្រចៀកដោយផ្សើមទឹកអប់បន្តិច ៗ ផង (ទឹកកូឡូញ)

អាទិត្យទី៤.– រៀនសាដើមឡើងវិញ

# កុមារដ្ឋាន

## វត្ថុស្វាធ្យាយន៍

អាទិត្យទី ១.– ១. អំពីខ្លួនមនុស្ស

គ្រូចាត់សិស្សម្នាក់ឲ្យទៅឈរនៅមុខ សិស្សឯទៀតសួរហើយ

ឲ្យសិស្សម្នាក់ៗបង្អុលប្រាប់សិស្សទាំងឡាយថា នេះហៅក្បាល? នេះលលាដ៍ក្បាល ។ល។ ត្រូវឲ្យសិស្សម្នាក់ៗស្ទាបក្បាលនិងលលាដ៍ក្បាលខ្លួនឯងរៀងរាល់គ្នា ។ល។

ពាក្យសួរ៖— ឯណាក្បាល ? ឯណាមុខ ? ក្បាលរាងដូចម្តេច ? ក្បាលភ្ជាប់ទៅនឹងដងខ្លួនដោយអ្វី ? សក់ដុះនៅឯណា ? សក់ក្មេងពណ៌ដូចម្តេច ចុះសក់មនុស្សចាស់វិញ ? នៅលើមុខមានអ្វីខ្លះ? ( ឲ្យសិស្សបង្អុលគ្រប់ៗគ្នា ) ភ្នែកសំរាប់ធ្វើអ្វី ? ចិញ្ចើមនឹងរោមភ្នែកប្រ-យោជន៍ដូចម្តេច ? ច្រមុះសំរាប់ធ្វើអ្វី ? នៅក្នុងមាត់មានអ្វីខ្លះ ? យើងស្តាប់យើងឮដោយសារអ្វី ? ។

## ២. ដងខ្លួន

គ្រូឲ្យសិស្សម្នាក់ទៅឈរនៅមុខសិស្សឯទៀត ហើយឲ្យដោះអាវចេញទើបលោកគ្រូបង្អុលអវយវៈផ្សេងៗ ។

ពាក្យសួរ៖— ឯណាហៅថាដងខ្លួន ? ដងខ្លួនខាងលើហៅថាអ្វី ? ខាងក្រោមហៅថាអ្វី ? ។ ឯណាឆ្អឹងជំនី ? ឯណាឆ្អឹងខ្នង ?

យើងពត់ខ្លួនបានទៅខាងណាខ្លះ ? ដោយហេតុអ្វី ។ ឆ្អឹងខ្នងយើងមិនមែនជាឆ្អឹងមួយដុំវែងនោះទេ គឺជាឆ្អឹងកំណាត់ខ្លីៗ ត្រួតៗ លើគ្នា ហេតុនេះហើយបានជាយើងពត់ខ្លួនទៅខាងណាក៏បាន ។ នៅក្នុងទ្រូងមានអ្វីខ្លះ ? (បើមានផ្ទាំងគំនូរត្រូវយកមកបង្ហាញសិស្សឲ្យស្គាល់សួត, បេះដូងហើយនឹងក្រពះ, ពោះវៀន, ថ្លើម, ប្រមាត់, ដែលនៅក្នុងពោះមើលពុំឃើញ) ។

អាទិត្យទី ២.— ១.— អវយវៈ លើក្រោម

សូមគ្រូធ្វើតាមរបៀបមុនៗ បង្អួលបង្ហាញសិស្ស ឯណាហៅថា ដៃ, ដើមដៃ, កែងដៃ, កំភួនដៃ, កដៃ, បាតដៃ, ខ្នងដៃ, ម្រាមដៃ, ថ្នាំងដៃ, ក្រចក, ជើង, ភ្លៅ, ជង្គង់, កំភួនជើង, កជើង, ភ្នែកគោរ, កែងជើង, បាតជើង, ខ្នងជើង, ម្រាមជើង ។ ត្រូវពន្យល់ប្រយោជន៍នៃសន្លាក់ដៃជើងនិមួយៗ ឲ្យសិស្សឃើញច្បាស់ ។

២.— ភ្នែក

អាទិត្យទី ៣ ១.— ត្របៀក ២.— ប្រមុះ ។

អាទិត្យទី ៤ ១.— អណ្ដាត ២.— ស្បែក ។

# បរិច្ឆណដ្ឋាន

## វិគ្ដស្មាធ្យាយន៍

អាទិត្យទី១ - 

### ១.–អាហារ

របស់សំរាប់បង្រៀន ៖ អង្ករ, ម្សៅនំបុ័ង, នំបុ័ង ។ នាំសិស្ស និយាយដោយសួរឲ្យឆ្លើយដូចមានរបៀបខាងក្រោមនេះ ៖

អ្នកបរិភោគអ្វីជាអាហារ ? ជាតិណាខ្លះបរិភោគបាយដូចយើង ? បារាំងបរិភោគបាយដូចយើងដែរឬទេ? ជាតិណាខ្លះដែលអាស្រ័យនំបុ័ង? គេចំអិនបាយដូចម្ដេច? នំបុ័ងយ៉ាងដូចម្ដេចន បើស៊ីបាយទទេបានឬទេ? ឯងអាស្រ័យបាយនឹងអ្វីខ្លះ? ។

### ២.– បន្លែ

របស់សម្រាប់បង្រៀន៖ ប៉េងប៉ោះ, ត្រប់, ជីរ, សាឡាត់, ដំឡូង, ផ្លែឈើ ។ ឲ្យសិស្សរកម្នាក់មួយមុខៗបន្លែឯទៀត ។

ពាក្យសួរ – យើងបរិភោគបន្លែណាខ្លះ? ឲ្យសិស្សម្នាក់ចាំបង្ហាញបន្លែមួយមុខៗ ។ បន្លែណាខ្លះដែលគេបរិភោគស្រស់ឆ្អិន? អន្លក់គេបរិភោគដូចម្ដេច? អ្វីខ្លះដែលយើងបរិភោគជាអន្លក់ (ស្លឹកកាំង,សាឡាត់, ជីរ) នៅ

ក្នុងដំឡូងមានជាតិអ្វី ? (កាត់ដំឡូងឆ្អិនមួយឲ្យសិស្សមើលជាតិម្សៅ) ។ បន្លែណាទៀតដែលមានជាតិម្សៅ ? ផ្លែឈើណាខ្លះដែលយើងបរិភោគជាអាហារពេលថ្ងៃ ?

## អាទិត្យទី ២ – ១ .– ត្រី

ឲ្យសិស្សរកត្រីស្រស់, ត្រីងៀត, ត្រីឆ្អើរ, ផ្អក, ប្រហុក ។

ពាក្យបោទ .– គេយកត្រីមកចំអិនធ្វើបានម្ហូបអ្វីខ្លះ ? បើចង់ទុកឲ្យបានយូរគេយកត្រីទៅធ្វើដូចម្ដេចខ្លះ ? គេប្រឡាក់, ឆ្អើរត្រីដូចម្ដេច? ។ល។ គេបរិភោគប្រហុករបៀបដូចម្ដេច ? ។

## ២ .– សត្វស្រុកដែលគេយកសាច់ជាអាហារ

របស់សំរាប់បង្រៀន .– សាច់ជ្រូក, សាច់គោ, សាច់ក្របី, សាច់មាន់ ។

## អាទិត្យទី ៣ .– ១ .– សត្វព្រៃដែលគេយកសាច់ជាអាហារ

## ២ .– ទឹកដោះគោ

របស់សំរាប់បង្រៀន .– ទឹកដោះគោឆៅ, ខ្លាញ់ប៊ឺរ៍, ហ្វ្រូម៉ាស, (បើមាន) ។

អាទិត្យទី ៤ .– ស៊ុត (ពង)

សូមគ្រូតែងពាក្យសួរផងចុះ ។

## កុមារដ្ឋាន

### វិធីបង្ការរោគ

អាទិត្យទី ១ .– ការថែរក្សាសក់

សូមគ្រូបង្រៀនតាមសៀវភៅវិធីបង្ការរោគទំព័រ ៤៣ ។

អាទិត្យទី ២.– ត្រូវធ្វើកុំឲ្យមានចៃ

សូមមើលក្នុងសៀវភៅដដែលទំព័រ ៤៦ ។

អាទិត្យទី ៣ .– ត្រូវមើលជម្ងឺមាស់

ជម្ងឺមាស់ពុំដែលជាឯងទេ ហេតុដូច្នេះត្រូវតែមើលដូចតាមរបៀបខាងក្រោមនេះ៖

ត្រូវដុសខ្លួននឹងសាប៊ូខ្មៅ ដុសក្ទួតឲ្យខ្ទាំងនឹងសាប៊ូខ្មៅ កមនេះនឹងបែកហើយមេអាត់នឹងពងអាត់របើកចេញពីរន្ធ រួចត្រូវឆ្លូតទឹកដុស

សាប៊ូលាបថ្នាំស្អាន់ដស់ទុកមួយថ្ងៃ ទើបជូតទឹកក្ដៅលាងខ្លួនចេញ ។ បើនៅមានមេអាត់ទៀតត្រូវធ្វើដដែលឡើងវិញម្ដងទៀត ។

ត្រូវស្ងោរខោអាវឲ្យស្អាតហើយដេកលើកំរាលស្អាត ។

អាទិត្យទី ៤.– សាបស្រៀនឡើងវិញ ។

## បរិប្ឋណាដ្ឋាន

### វិធីបង្ការរោគ

អាទិត្យទី ១.– ១– ត្រូវបរិភោគល្មមសមគួរ

មើលក្នុងសៀវភៅវិធីបង្ការរោគទំព័រ២៤

២- ត្រូវបរិភោគអាហារដែលល្អឥតទោស ។

អាទិត្យទី ២.– ១- ត្រូវបេះផ្សំចំណីអាហារ

២- ត្រូវចំអិនសាច់នឹងអាហារឲ្យល្អ

អាទិត្យទី ៣.– ៤- ត្រូវបរិភោគតាមសំរួលហើយទំពាឲ្យល្អិតផង

សូមមើលក្នុងសៀវភៅវិធីបង្ការរោគចុះ ។

# លោកនីតិ

## សំរាប់គ្រប់ថ្នាក់

### អំពីសំបុត្រកំណើត

សំបុត្រកំណើតមានប្រយោជន៍ណាស់ ហេតុនេះត្រូវកុំធ្វេសប្រហែសឲ្យសោះ បើមានកូនកើតក្នុងរវាងបីថ្ងៃត្រូវរកសាក្សីបានពីរនាក់ ហើយនាំគ្នាទៅសាលាឃុំ ប្ដឹងសុំចុះកំណើតកុមារនោះហើយត្រូវសុំចម្លងកំណើតមួយច្បាប់ទុកប្រើការទៅថ្ងៃក្រោយ ដូចចូលទៅរៀនក្នុងសាលាឬបង់កាតឬបួសឬទាស់ទែងគ្នាដល់តុលាការអំពីសម្បត្តិមត៌កក្ដី ត្រូវមានជាតិសញ្ញាប័ត្រដំរាប ។

បើនៅក្រុងភ្នំពេញ កាលណាមានកូនកើតត្រូវទៅប្ដឹងមេសង្កាត់(មេឃុំ)ក្នុងពេលដែលកើតនោះ ទើបមេឃុំចេញសំបុត្រមួយឲ្យគាត់យកទៅមន្ទីរពេទ្យបាលរោគ ដើម្បីឲ្យពេទ្យការការពាររោគ ទៅបណ្ដុះអុតកុមារនោះភ្លាម រួចបាននាំទៅចុះកំណើតនៅសាលាឃុំវិញក្នុងកំណត់បីថ្ងៃ ។

ពាក្យសួរចោទ បើមានកូនកើតត្រូវធ្វើដូចម្ដេច ? នៅភ្នំពេញគេធ្វើដូចម្ដេចទៀត ? បើមិនបានទៅប្ដឹងមេឃុំឲ្យចុះកំណើតទេ នោះនឹងមានទោសដូចម្ដេច ? (លក់ពិន័យ) សំបុត្រកំណើតមានប្រយោជន៍យ៉ាងដូចម្ដេចខ្លះ ? ។

## សំបុត្រអាពាហ៍ពិពាហ៍ (អាវាហវិវាហ)

មុននឹងរៀបការកូនប្រុសស្រី ត្រូវមាតាបិតាខាងកូនស្រីទៅប្ដឹងមេឃុំ ចំនួន៨ថ្ងៃមុនរៀបមង្គលនេះ មេឃុំត្រូវចេញសំបុត្រមួយប្រាប់មានចុះឈ្មោះស្វាមីខ្លួនប្រុសស្រីហើយបញ្ញត្តថា បើឈ្មោះណាមានទាក់ទងនឹងរឿងនេះ នឹងអ្នកនេះត្រូវប្ដឹងតវ៉ាក្នុងរវាង៨ថ្ងៃមុននឹងរៀបអាវាហវិវាហ តែបើហួសកំ- ណត់ថ្ងៃនេះហើយនឹងទុកជាស្រេច លុះរៀបអាពាហ៍ពិពាហ៍ស្រេចហើយ មាតាបិតានឹងកូនប្រុសស្រីមានសាក្សីពីរនាក់ នាំគ្នាទៅចុះអេតាស៊ីវិល នៅសាលាឃុំ រួចសុំសំណៅមួយសន្ទឹកទុកប្រើការទៅពេលក្រោយ ពីព្រោះមានច្បាប់បញ្ញត្តិថា នរណាយកគ្នាជាប្ដីប្រពន្ធពុំបានចុះអេតាស៊ីវិល នោះមិនពេញជាប្ដីប្រពន្ធទេ បើមានហេតុទាស់ទែងលែងលះគ្នានោះ រាជការមិនទទួលបណ្ដឹងឡើយ បដិសេធចោលជាអសារឥតការ ។

សួរចោទ .– សូមសួរចោទនាំសិស្សនិយាយឲ្យបានរេះប្រាកដ ដូចមានរបៀបមុន ៗ ស្រាប់ ៗ

## មរណភាព

របៀបកើតនិងស្លាប់មិនប្លែកគ្នាប៉ុន្មានទេ នៅទីក្រុងបើមានមនុស្សស្លាប់គេទៅប្តឹងសុំសំបុត្រមេឃុំ រួចយកសំបុត្រនោះទៅមន្ទីរការពាររោគ ដើម្បីឲ្យគ្រូពេទ្យទៅពិនិត្យ មើលខ្មោចនោះ តើស្លាប់ដោយរោគអ្វី ៗ លុះពេទ្យពិនិត្យមើលត្រឹមត្រូវហើយទើបអនុញ្ញាតឲ្យយកខ្មោចនោះទៅកប់ឬបូជាតាមកំណត់ពេលវេលា ដែលគ្រូពេទ្យបានបញ្ជាក់ក្នុងសំបុត្រនោះស្រាប់ ៗ រួចពីនោះមកបីថ្ងៃទើបបានគេនាំគ្នាទៅចុះមរណភាពឯសាលាឃុំដូចជាចុះកំណើតនោះដែរ ៗ

# មេសូត្រតែមាត់

(គ្រប់ថ្នាក់)

## វិធីបង្ការរោគ

ឯក្បួនវិធីបង្ការរោគ គឺលោកប្រដៅឲ្យបានសុខ
ជៀសវាងជម្ងឺទៅថ្ងៃមុខ ច្បាប់នេះចាំទុកជាកុំខាន ។
ត្រូវដុសលាងសំលៀកបំពាក់ ដែលអ្នកបិទបាំងកាយប៉ុន្មាន
ហើយត្រូវសំអាតឲ្យស្អាតប្រាណ ទើបបានសេចក្ដីសុខសប្បាយ ។
ឯផ្ទះត្រូវបោសប្រាសប្រក្រតី អាហារចំណីអ្វីទាំងឡាយ
ត្រូវស្អាតទើបគ្មានរោគក្នុងកាយ នឹងបរិភោគបាយឲ្យឆ្អែតល្មម ។
ឆ្អែតហួសព្រោះឈឺក្រពះបាយ នាំក្លាយជារោគឈឺស្គាំងស្គម
ក្រចកត្រូវកាត់ឲ្យស្អាតព្រម ចាប់ពមអាហារគ្មានក្អែលជាប់ ។
ឯទឹកយើងត្រូវផឹកទឹកថ្លា ដាំឆ្អិនដល់ការនោះទើបគាប់
ស្រាផឹកទៅពុលគ្មានគេរាប់ អាគៀនញៀនជាប់ថ្លាប់ខូចខ្លួន ។

---

ពន្យល់ពាក្យ ៈ— សំលៀកបំពាក់ = ខោអាវ ។ រោគ = ជម្ងឺ ។
ក្លាយ = ប្រែប្រួល ។ ពម = បរិភោគ ។ ពុល = ដែល
មានពិសបណ្ដាលឲ្យក្អួតចង្អោររង៉ាប់រងើ ។

# ២.- ការរំលាយអាហារ

មនុស្សយើងបានរស់ជីវិត ត្រូវតែពិតបរិភោគអាហារ
ទើបបានរស់រូបនៃជីវ៉ា តែអត់អាហារនោះនឹងស្លាប់ ។
ហេតុនេះបរិភោគអាហារ ដល់មាត់កាលណាកុំប្រញាប់
ទើបថ្គាមធ្មេញរំអិតឲ្យឆាប់ ទឹកមាត់សម្រាប់ផ្សើមអាហារ ។
ហើយបានអណ្ដាតរុញច្រានទៅ សំដៅបំពង់កនោះណា
លុះដល់ប្លោកមួយធំណាស់សា ប្លោកនោះហៅថាក្រពះបាយ ។
ទីនោះមានអាបោធាតុមួយ បន្ទុំរលួយភោជន៍ទាំងឡាយ
ល្អិតស្រេចមែនទែនតាំងខ្ចល់ខ្ចាយ ហើយចេញប្រញាយទៅពោះវៀន ។
អាហារនោះចែកជាពីរផ្លូវ មួយបញ្ចេញទៅក្រៅក៏មាន
មួយនៅសំរាប់ទឹនពោះឃ្លាន ទើបមានជីវិតតទៅទៀត ។

---

ពន្យល់ពាក្យ .- ជីវ៉ា = រស់នៅ ។ រំអិត = ធ្វើឲ្យខ្ទេច ។
ផ្សើម = ធ្វើឲ្យសើម ។ ប្លោក = ថង់ក្រពះ ។
អាបោធាតុ = ធាតុទឹក ។ ភោជន៍ បាយ = ។

# ៣.–ការដកដង្ហើម

មនុស្សយើងត្រូវការដកដង្ហើម ជាប្រយោជន៍ឆ្មើមនៃជីវិត
ខានដកកាលណានោះស្លាប់ពិត ព្រោះគ្មានខ្យល់ជិតដល់ចូលនៅ ៗ
ខ្យល់ដែលយើងដកដង្ហើមចូល ប្រមូលតាមរន្ធច្រមុះកូវ
ខ្វះចូលតាមមាត់មិនឈប់នៅ តាមបំពង់ទៅសួតនោះណា ៗ
លុះខ្យល់ចូលក្នុងសួតហ៉ានក្អែត ទើបហើបអណ្ដែតនៃឧរា
ដល់ដកដង្ហើមចេញកាលណា សួតផតកាយោក្ដាប់រួបវិញ ៗ
ហេតុនេះយើងដកដង្ហើមទៅ ខានមាត់មិនត្រូវឲ្យចូលចេញ
ត្រូវដកតែពីច្រមុះវិញ ទើបខ្យល់ចូលចេញសុទ្ធតែល្អ ៗ

---

ពន្យល់ពាក្យ ៖– ឆ្មើម = វិសេស ។ ឧរា = ទ្រូង ។ កាយោ = (ពាក្យសំរួលមាត់) គឺកាយ = រូបដែលជាទីប្រជុំអាការៈ ៣២ មានសក់ រោម ក្រចកជាដើម ។ សួត = អាការៈសំរាប់ដកដង្ហើមចេញចូល ។

# ៥.- ចូរខំធ្វើការ

យើងត្រូវខំធ្វើការគ្រប់គ្នា ទោះជាពិបាកដូចម្ដេចក្ដី
ព្រោះមនុស្សគ្រប់រូបក្នុងលោកិយ បានអ្វីមកពីខំធ្វើការ ។
មនុស្សយើងឲ្យមានទីលំនៅ យើងត្រូវបរិភោគអស់អាហារ
សំពត់អាវបិទបាំងអាត្មា មិនដែលអ្នកណាបានទទេ ។
ត្រូវធ្វើប្ដូរទិញទើបបានមក លុះតែយើងរកប្រាក់ទិញគេ
បើចង់បានប្រាក់ត្រូវរិះរេ កុំនៅទំនេរធ្វើការ ។
ការនេះមានគុណប្រសើរណាស់ នាំកុំខ្ជិលផ្លាស់ត្រូវឧស្សាហ៍
ការនេះនាំឲ្យមានប្រាជ្ញា ឲ្យមានកិរិយាល្អប្រពៃ ។
មួយទៀតចំណែកខាងធនធាន នឹងមានសម្បត្តិតិចច្រើនក្ដី
ហេតុនេះចូរកុមារប្រុសស្រី គប្បីត្រូវអ្នកខំធ្វើការ ។

---

ពន្យល់ពាក្យ .- លោកិយ = លោកនេះ = អាត្មា = ខ្ញុំ ... ឯង .. អញ ..យើង។
ឧស្សាហ៍ = ប្រឹងប្រែង, សង្វាត ។ ប្រពៃ = ប្រសើរ ។ ធនធាន = សម្បត្តិ ។

## ៥.— ត្រូវកាត់ចិត្តអំណត់

នាងអើយត្រូវកាន់ចិត្តអំណត់ ទំរត់ទោះខឹងជួបមេត្តក្ដី
មនុស្សខឹងរាល់រូបទាំងប្រុសស្រី ធ្វើអ្វីបានគ្មានដែលត្រូវ ។
បាត់ខឹងទើបដឹងជាខ្ញុំខុស ធ្វើហួសជួបខ្មោះស្ដាយក្រោយក្ងូវ
ដូចមាននិទានពីឈ្មោះតៅ លំនៅនៃគាត់ឃុំបែកចាន ។
ពេលព្រឹកតៅចេញទៅភ្ជួរស្រែ ប្រឹងតែភ្ជួរដីគ្មានស្រាកស្រាន្ត
លុះដល់ថ្ងៃត្រង់ក្ដៅដល់ប្រាណ ទើបបានត្រឡប់វិលមកផ្ទះ ។
ឃើញប្រពន្ធកំពុងដាំបាយ ខឹងក្ដៅក្រហាយជេរដៀលត្នះ
ព្រោះគាត់ឃ្លានបាយកាយញ័រណាស់ ប្រឹងស្ទុះទៅទះប្រពន្ធប៉ាំង ។
ត្រូវក្អកបែកចេញឈាមសស្រាក់ ហើមខ្លាក់ក្អកម្នាងឈឺជាខ្លាំង
រកថ្នាំចិនសែខ្មែរបារាំង រកទាំងគ្រូមើលក៏ពុំជា ។
ប្រពន្ធងើតងិតក្អកទៅ តៅឃើញប្រពន្ធរងវេទនា
មានចិត្តអាណិតដល់ភរិយា ស្ដាយក្រោយដែលវាខឹងច្រឡះហាន ។

ពន្យល់ពាក្យ.—ស្រាកស្រាន្ត=គ្មានបង្អង់ ។ ត្នះ=ឲ្យគាប់មុខ ។ វេទនា=សោយអារម្មណ៍ ។ ភរិយា=ប្រពន្ធ ។

រោងពុម្ពខ្មែរ